ការកាត់ដីសរុបទំហំ ២.៥៤៩ ហិកតា នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.១១១ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៧២ លខ.កច ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ **២.៥៤៩ ហិកតា** ក្នុងនោះ (១) ទំហំ **៣៥ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ **២.៥១៤ ហិកតា** កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលស្ថិតក្នុងភូមិដូចខាងក្រោម៖

- កាត់ផ្ទៃដីសរុបទំហំ **១៦៧ ហិកតា** ក្នុងនោះ (១) ទំហំ **១១ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ **១៥៦ ហិកតា** កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **នៅភូមិខ្វយ ១**
- កាត់ផ្ទៃដីទំហំ **៣៧៥ ហិកតា** ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **នៅភូមិខ្វយ ២**
- កាត់ផ្ទៃដីសរុបទំហំ **៧០៦ ហិកតា** ក្នុងនោះ (១) ទំហំ **០៣ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ **៧០៣ ហិកតា** កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **នៅភូមិខ្វយ ៣**
- កាត់ផ្ទៃដីសរុបទំហំ **១៦២ ហិកតា** ក្នុងនោះ (១) ទំហំ **២១ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង(២)ទំហំ **១៤១ ហិកតា** កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **នៅភូមិអូរប្រឡោះ**
- កាត់ផ្ទៃដីទំហំ **១.១៣៩ ហិកតា** ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស់ រីសូសលីមីធីត សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **នៅភូមិអូរកាប់មាន់**

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ១.១១១ គ្រួសារ នៅឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលស្ថិតក្នុងភូមិដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៨៩ គ្រួសារ នៅភូមិខ្ទួយ១
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៤៦ គ្រួសារ នៅភូមិខ្ទួយ២
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣១៧ គ្រួសារ នៅភូមិខ្ទួយ៣
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៣ គ្រួសារ នៅភូមិអូរប្រឡោះ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣១៦ គ្រួសារ នៅភូមិអូរកាប់មាន់ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩០ . អនក្រ . បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅ
របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣១៧ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដែលហៅកាត់ថាអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**.។

ជំពូកទី២
តួនាទីនិងភារកិច្ច

មាត្រា ២.-

អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាលនិងបច្ចេកទេសដែលធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់**គ.ជ.គ.ក.**
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទទួលបានការយល់ព្រមពី**គ.ជ.គ.ក.** ដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- គ្រប់គ្រងហិរញ្ញវត្ថុរបស់ **គ.ជ.គ.ក.**
- ពិនិត្យតាមដាន វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច
- លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូចជូន**គ.ជ.គ.ក.**
- សហការជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ
- ធ្វើរបាយការណ៍ជូន**គ.ជ.គ.ក.**
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែល**គ.ជ.គ.ក.**ប្រគល់ជូន។

ជំពូកទី៣
រចនាសម្ព័ន្ធនិងការគ្រប់គ្រង

មាត្រា ៣.-

អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែកគោលនយោបាយ
- ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ផ្នែកពិនិត្យតាមដាននិងវាយតម្លៃ។

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូបដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួនតាមការចាំបាច់។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៤._

ផ្នែកគោលនយោបាយមានតួនាទីនិងភារកិច្ចៈ

- លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូចជូន **គ.ជ.គ.ក.**
- សម្របសម្រួលជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យដើម្បីអភិវឌ្ឍសមត្ថភាពដល់អ្នកពាក់ព័ន្ធ
- សហការជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីធានាប្រសិទ្ធភាពការងាររបស់**គ.ជ.គ.ក.**
- សិក្សាស្រាវជ្រាវពីការគាំពារនិងការអភិវឌ្ឍកុមារតូចដើម្បីចងក្រងជាឯកសារសម្រាប់ជាធនធានដល់អ្នកសិក្សាស្រាវជ្រាវ
- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ដើម្បីពង្រីកការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច
- សហការជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ ដើម្បីធានាការអនុវត្តតួនាទីនិងភារកិច្ចដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** ប្រគល់ជូន។

មាត្រា ៥._

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចៈ

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលទទួលបានការយល់ព្រមពី**គ.ជ.គ.ក.** ដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- បូកសរុបការងារពាក់ព័ន្ធនឹងការគាំពារនិងការអភិវឌ្ឍកុមារតូចដាក់ជូន**គ.ជ.គ.ក.** ដើម្បីពិនិត្យនិងសម្រេច
- បំពេញការងាររដ្ឋបាលនិងធានានិរន្តរភាពការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាន **គ.ជ.គ.ក.**
- រៀបចំនិងចាត់ចែងកិច្ចប្រជុំរបស់**គ.ជ.គ.ក.**
- ធ្វើរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.**
- គ្រប់គ្រងចំណូល ចំណាយ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់**គ.ជ.គ.ក.**
- រៀបចំនិងគ្រប់គ្រងបញ្ជីសារពើភណ្ឌចលនទ្រព្យនិងអចលនទ្រព្យរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍ និងលើកអនុសាសន៍ជូន**គ.ជ.គ.ក**. ពិនិត្យនិងសម្រេច
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. ប្រគល់ជូន។

មាត្រា ៦.-

ផ្នែកពិនិត្យតាមដាននិងវាយតម្លៃ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យសម្រាប់ការពិនិត្យតាមដាននិងការវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារ និងការអភិវឌ្ឍកុមារតូច
- ស្រាវជ្រាវនិងកំណត់សូចនាករចំណុចដៅសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃ
- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍ ដើម្បីកែលម្អយន្តការពិនិត្យតាមដាននិងវាយតម្លៃ
- ប្រមូលទិន្នន័យនិងវិភាគលើលទ្ធផលការអនុវត្តគ្រប់កម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច ដើម្បីដាក់ជូន**គ.ជ.គ.ក**. ពិនិត្យ
- ផ្សព្វផ្សាយលទ្ធផលនៃការពិនិត្យតាមដាននិងការវាយតម្លៃដល់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. ប្រគល់ជូន។

មាត្រា ៧.-

អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. មានមន្ត្រីបម្រើការមកពីក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. អាចមានអ្នកជំនាញការនិងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន។

មាត្រា ៨.-

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីនិងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**.។

បែបបទនិងនីតិវិធីអនុវត្តការងារក្នុងអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០១៣
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅ
របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន គ.ជ.គ.ក.



សម្គាល់

- ទំនាក់ទំនងប្រយោល ·········►
- ទំនាក់ទំនងផ្ទាល់ ————►
- គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច(**គ.ជ.គ.ក.**)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩១ . អនក្រ . បក

អនុក្រឹត្យ
ស្តីពី
ការបង្កើត និងដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើត និងការដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សម្រេច

មាត្រា១.-

ត្រូវបានបង្កើត និងដាក់ឲ្យដំណើរការបន្ថែមទីភ្នាក់ងារប្រតិបត្តិការពិសេសចំនួន០៦នៅតាមបណ្តាអង្គភាពសុខាភិបាល នៃក្រសួងសុខាភិបាល មានដូចខាងក្រោម ៖

១- មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង

២- មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង

៣- មណ្ឌលសុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្ទឹងត្រែង ខេត្តស្ទឹងត្រែង

៤- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

៥- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៦- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាកាន ខេត្តពោធិ៍សាត់ ។

មាត្រា២.-

ទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ គឺជាភ្នាក់ងារមួយរបស់ក្រសួងសុខាភិបាល ដែលមានមុខងារពិសេសក្នុងការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ហើយស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងសុខាភិបាល និងមានភារកិច្ចចម្បងៗ ដូចខាងក្រោម ៖

- ផ្តល់សេវាសុខភាពសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា
- លើកកម្ពស់ការគ្រប់គ្រងផ្អែកលើលទ្ធផលការងារ សំដៅកែប្រែផ្នត់គំនិត និងអាកប្បកិរិយាមន្ត្រីរាជការ ស្របតាមលក្ខណសម្បត្តិរបស់រដ្ឋបាលសាធារណៈ
- អភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងការផ្តល់សេវាសុខាភិបាលសាធារណៈ។

ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនីមួយៗមានតួនាទីសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងការងារគ្រប់គ្រងដល់អង្គភាពសុខាភិបាលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

មាត្រា៣.-

ទីភ្នាក់ងារប្រតិបត្តិការពិសេសដែលជាមន្ទីរពេទ្យបង្អែកខេត្ត ដូចមានក្នុងមាត្រា១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមន្ទីរពេទ្យបង្អែកខេត្តនីមួយៗ។

ទីភ្នាក់ងារប្រតិបត្តិការពិសេសដែលស្ថិតនៅតាមបណ្តាការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដូចមានចែងក្នុងមាត្រា១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនីមួយៗ។

មាត្រា៤.-

សិទ្ធិ និងការទទួលខុសត្រូវរបស់ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាល ត្រូវកំណត់ឲ្យបានច្បាស់លាស់នៅក្នុងលក្ខខណ្ឌបេសកកម្ម និងក្នុងកិច្ចសន្យាគ្រប់គ្រង។

លក្ខខណ្ឌបេសកកម្ម និងកិច្ចសន្យាគ្រប់គ្រងគំរូ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា៥.-

ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស នៃបណ្ដាអង្គភាពសុខាភិបាលនីមួយៗត្រូវទទួលខុសត្រូវក្នុងដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះប្រធានមន្ទីរសុខាភិបាលខេត្តដែលទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ ។

មាត្រា៦.-

មន្ត្រីដែលបម្រើការងារក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៅតាមបណ្ដាអង្គភាពនៃក្រសួងសុខាភិបាល ដូចបានកំណត់ក្នុងមាត្រា១ ជាមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ឬ បុគ្គលិកជាប់កិច្ចសន្យាដែលកំពុងបម្រើការងារក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រសួងសុខាភិបាល។

មន្ត្រីរាជការ និងបុគ្គលិកទាំងនេះ ត្រូវចុះកិច្ចសន្យាការងារជាមួយប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ តាមរយៈអ្នកគ្រប់គ្រងមន្ត្រីផ្ទាល់។

មាត្រា៧.-

មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ដែលបម្រើការងារនៅក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តដែលបានមកពីការបែងចែកប្រាក់សេវាហិរញ្ញប្បទាន ប្រាក់ធានារ៉ាប់រងសង្គម ប្រាក់មូលនិធិសមធម៌ និងប្រាក់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ បន្ថែមលើប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស។

កម្រិតប្រាក់ឧបត្ថម្ភលើកទឹកចិត្តខាងលើនេះ ត្រូវអនុវត្តតាមការណែនាំជាក់ស្ដែងរបស់ក្រសួងសុខាភិបាល។ បន្ថែមលើនេះ ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ អាចផ្ដល់ជូនប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិកទៅតាមលទ្ធផលការងារ និងស្ថានភាពជាក់ស្ដែង នៃទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ។

មាត្រា៨.-

ការបើកប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវធ្វើឡើងនៅតាមអង្គភាពដែលទីភ្នាក់ងារប្រតិបត្តិការពិសេសគ្របដណ្ដប់ តាមរយៈការបើកផ្ដល់ដោយផ្ទាល់ដៃ ឬតាមប្រព័ន្ធធនាគារ។

មាត្រា៩.-

ប្រភពធនធាន និងចំណូលថវិការបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលបានមកពី៖

- ថវិកាជាតិ
- ប្រាក់សេវាហិរញ្ញប្បទាន
- ប្រាក់ធានារ៉ាប់រងសង្គម
- ប្រាក់មូលនិធិសមធម៌ និង
- ប្រាក់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍។

មាត្រា១០.-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍វិស័យសុខាភិបាលត្រូវធានាថវិកាដែលត្រូវផ្តល់ឲ្យទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗបានទាន់ពេលវេលា។

ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលជាសេនាធិការ មានតួនាទី សម្របសម្រួល ជំរុញ និងតាមដានការអនុវត្តរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសទាំងនេះ។

មាត្រា១១.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា១២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាលរដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សុខ អាន

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ២.៥៦៧ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន រ័ត្នសម្បត្តិ និងកាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៧៦ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤១៣/៣៧៩ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៤២២ ខបប ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ២.៥៦៧ ហិកតា ក្នុងនោះ (១) ទំហំ ១.៤១៤,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស តាមព្រះរាជក្រឹត្យ លេខ នស/រកត/០៤១៣/៣៧៩ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៣ (២) ទំហំ ៩១៦ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុនយូរីសាគរ (៣) ទំហំ ១០០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនវ័ត្តសម្បត្តិ និង (៤) ទំហំ ១៣៦,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ២.៥០២,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៧៦ គ្រួសារ និង ៦៤,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ) នៅឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១៤១,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរនៃនោង
- កាត់ផ្ទៃដីសរុបទំហំ ៨២៤ ហិកតា ក្នុងនោះ (១) ទំហំ ៤០៨,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស (២) ទំហំ ៣០៧,៥ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ និង (៣) ទំហំ ១០៨ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សី

របស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្ម ៧៥៩,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៨,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ) នៅភូមិអូរក្រូច

- ផ្ទៃដីទំហំ ៩៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរគ្រែង
- ផ្ទៃដីទំហំ ១១៣,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤២ គ្រួសារ នៅភូមិពាមតា
- ផ្ទៃដីទំហំ ១៦៣,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិពាម
- កាត់ផ្ទៃដីសរុបទំហំ ៨៣២,៥ ហិកតា ក្នុងនោះ (១) ទំហំ ១០៦ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស (២) ទំហំ ៥៩៨ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ (៣) ទំហំ ១០០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វត្តសម្បត្តិ និង (៤) ទំហំ ២៨,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មទំហំ ៨៣២,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរតាទៀក
- កាត់ផ្ទៃដីសរុបទំហំ ២៣៤,៥ ហិកតា ក្នុងនោះ (១) ទំហំ ២២៤ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស (២) ទំហំ ១០,៥ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិតាគោក
- ផ្ទៃដីទំហំ ១៦២,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិវាលរលឹម

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ២.៩៧៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៨ គ្រួសារ នៅភូមិអូរនេនាង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣១០ គ្រួសារ នៅភូមិអូរក្រូច
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១ គ្រួសារ នៅភូមិអូរគ្រែង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤២ គ្រួសារ នៅភូមិពាមតា
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៣ គ្រួសារ នៅភូមិពាម
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៤៧ គ្រួសារ នៅភូមិអូរតាទៀក

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២៥ គ្រួសារ នៅភូមិតាគោក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២០ គ្រួសារ នៅភូមិវាលរលឹម ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤១.អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥២អនក្រ.បក ចុះថ្ងៃទី២១ខែកញ្ញាឆ្នាំ២០១២ ស្តីពីការបង្កើតវិទ្យាស្ថានប្រវត្តិសាស្ត្រយោធា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន ឧត្តមសេនីយ៍ទោ **ពីន សេដ្ឋដុល** អត្តលេខ ០០០៥៩៥ ជា នាយក វិទ្យាស្ថានប្រវត្តិសាស្ត្រយោធា អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៣
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៤៧...អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ	**ខៀវ សុខុម**	អត្តលេខ	០១៨៤១
២- លោកវរសេនីយ៍ទោ	**ហង្ស ចាន់សុទ្ធី**	អត្តលេខ	០២០៩៥
៣- លោកវរសេនីយ៍ទោ	**សិទ្ធិ ឡោះ**	អត្តលេខ	០៩០៤៩
៤- លោកវរសេនីយ៍ទោ	**អ៊ិន ម៉ុន្នីរិទ្ធ**	អត្តលេខ	១២២៤៨
៥- លោកវរសេនីយ៍ទោ	**ញ៉ៀម ខន**	អត្តលេខ	១២៣០៦ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៣.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន៣៨រូប ដែលមានស្នាព្រះហស្ត ស្នាដៃល្អក្នុងការចលនាពុទ្ធបរិស័ទ និងបរិច្ចាគបច្ច័យ ថវិកា ចូលរួមយ៉ាងសកម្មជាមួយសម្តេចព្រះសង្ឃនាយក ជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅក្នុងវត្តអម្ពវ័ន ហៅវត្តព្រៃធ្លូរ ភូមិព្រៃធ្លូរ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ និងតាមមូលដ្ឋាននានាជាច្រើនទៀត ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ព្រះតេជគុណ	ខ៉ែន	ខៃ	ព្រះគ្រូចៅអធិការវត្តអម្ពវ័ន ហៅ ព្រៃធ្លូរ
២-ព្រះតេជគុណ	ពៅ	ថុល	ព្រះគ្រូចៅអធិការស្តីទី វត្តអង្គប្រីយ៍
៣-ឧបាសក	មុំ	មាន	សប្បុរសជនរាជធានីភ្នំពេញ
៤-លោក	ជាវ	ប៊ុនរិទ្ធ	សប្បុរសជនរាជធានីភ្នំពេញ
៥-លោក	ញេប	សារិន	សប្បុរសជនរាជធានីភ្នំពេញ
៦-លោក	ចំនួ	សុវណ្ណា	សប្បុរសជនរាជធានីភ្នំពេញ
៧-លោក	ដួង	វ៉ាន	ប្រធានមន្ទីរស្តីទីធម្មការនិងសាសនាខេត្តតាកែវ
៨-លោក	រតនៈ	សម្បត្តិ	សប្បុរសជនរាជធានីភ្នំពេញ
៩-លោក	អ៊ួន	សុខុម	អធិការរងស្រុកត្រាំកក់
១០-លោក	ឈាប	មាន	មេឃុំពពេល
១១-អ្នកស្រី	ថុង	ណែម	សប្បុរសជនរាជធានីភ្នំពេញ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-ព្រះតេជគុណ	ម៉ែន	សាវឿន	គង់នៅវត្តបទុមវតី រាជធានីភ្នំពេញ
២-ព្រះតេជគុណ	នេត	គន្ធី	គង់នៅវត្តបទុមវតី រាជធានីភ្នំពេញ
៣-ព្រះតេជគុណ	ធី	ម៉ានី	គង់នៅវត្តអង្គប្រិយ៍
៤-ឧបាសិកា	ញូ	សារឹម	សប្បុរសជន ខេត្តតាកែវ
៥-លោក	ចាន់	ម៉ុន	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា
៦-អ្នកស្រី	មុំ	សុផាត	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា
៧-លោក	គាំ	ជាំផេង	អនុប្រធានមន្ទីរធម្មការនិងសាសនា ខេត្តតាកែវ
៨-លោក	ប៊ុក	ខិនហេង	សប្បុរសជននៅរាជធានីភ្នំពេញ
៩-អ្នកស្រី	ភាំង	ឆហួរ	សប្បុរសជននៅរាជធានីភ្នំពេញ
១០-លោក	គាវ	ឆាយ	សប្បុរសជននៅរាជធានីភ្នំពេញ
១១-លោក	មាស	វណ្ណា	សប្បុរសជននៅរាជធានីភ្នំពេញ
១២-អ្នកស្រី	ជុក	គីមហេង	សប្បុរសជននៅខេត្តតាកែវ
១៣-លោក	ញៀប	ឃឿន	សប្បុរសជននៅខេត្តតាកែវ

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោក	យ៉ែម	វុន	នាយករងអនុវិទ្យាល័យព្រៃជ្វូរ
២-លោក	សំ	ម៉ន	ប្រធានភូមិព្រៃជ្វូរ
៣-ឧបាសក	អ៊ុ	អាន់	ប្រធានអាចារ្យវត្តព្រៃជ្វូរ
៤-ឧបាសក	ឡុង	ឡុញ	អនុប្រធានអាចារ្យវត្តព្រៃជ្វូរ
៥-ឧបាសក	អ៊ួង	ផន	អនុប្រធានអាចារ្យវត្តព្រៃជ្វូរ
៦-ឧបាសក	គីម	គង់	ប្រធានគណៈកម្មការសាងសង់វត្តព្រៃជ្វូរ
៧-ឧបាសក	ស្រី	នួន	សមាជិកគណៈកម្មការវត្តព្រៃជ្វូរ
៨-ឧបាសក	មិន	គៀត	សមាជិកគណៈកម្មការវត្តព្រៃជ្វូរ
៩-ឧបាសក	ព្រុំ	តុស	សមាជិកគណៈកម្មការវត្តព្រៃជ្វូរ
១០-ឧបាសក	អិន	យន់	សមាជិកគណៈកម្មការវត្តព្រៃជ្វូរ
១១-ឧបាសក	លុយ	ស៊ីសុប៊ិន	សមាជិកគណៈកម្មការវត្តព្រៃជ្វូរ
១២-ឧបាសក	ជុំ	សំ	សមាជិកគណៈកម្មការវត្តព្រៃជ្វូរ
១៣-ឧបាសក	ថៃត	វន	ជំនួយការគណៈកម្មការវត្តព្រៃជ្វូរ
១៤-ឧបាសក	អោម	ខុម	ជំនួយការគណៈកម្មការវត្តព្រៃជ្វូរ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១២រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	ហៀង	សុជាតិ	៧-កញ្ញា	ប៉ុល	ចិន្តា
២-លោក	ម៉ម	សុភក្រ្ត	៨-លោក	ស៊ុំ	សុខៃ
៣-លោក	ហាំ	ផាន្នី	៩-លោក	ឃុត	រដ្ឋា
៤-លោក	ជុំ	ទុន្ធី	១០-លោក	កែម	សុខៃ
៥-លោក	កែវ	សុវណ្ណនី	១១-លោក	ឿន	រត្នសិរិតស័ក
៦-កញ្ញា	ខាន់	សុម៉ល់	១២-លោក	ឈុំ	កិត្តិគុណ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១១រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	ប៊ុត	តិរម្យ	៧-លោក	ទ៉ា	សំបូរ
២-កញ្ញា	សេរី	សុរិយា	៨-លោក	ស្រួយ	សក្កដា
៣-លោក	សេរី	បណ្ឌិត	៩-កញ្ញា	ប៉ែន	សុភាយ៉ា
៤-លោក	សុខ	គីមផង	១០-លោក	មាស	លីនណា
៥-លោក	លី	រតនា	១១-លោក	លឹម	ស៊ានឌីណាំង
៦-លោក	គង់	សីតុលា			

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៩៦.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនយុវជន ចំនួន១១រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	ចាន់	សុធី	៧-លោក	ពុត	សារ៉ាន
២-កញ្ញា	ម៉ុក	ចំន្ទធីតា	៨-លោក	ពេជ	ភន្ថា
៣-លោក	ឆាយ	សុផាន់ណា	៩-លោក	ព្រំ	បូរ៉ា
៤-លោក	ជូ	សុភ័ក្ត	១០-លោក	ហៅ	ស៊ាចហ៊ុយ
៥-កញ្ញា	ឈូក	មករា	១១-លោក	ជៃ	ចាន់ថន
៦-លោក	ម៉ុត	ភួង			

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤៧. អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១១រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	**សឹង**	**សារ៉េត**	៧-លោក	**សំ**	**កោសល្យ**
២-កញ្ញា	**ខែល**	**សេងលី**	៨-លោក	**រាជ**	**ម៉ានីឡា**
៣-កញ្ញា	**សោម**	**បុប្ផា**	៩-លោក	**មុំ**	**សុផល**
៤-កញ្ញា	**ហាស់**	**ស៊ីនាថ**	១០-លោក	**ថ័រ**	**ធីម**
៥-លោក	**ឡុង**	**សុផុន**	១១-លោក	**សុខ**	**ចាន់ដារ៉ា**
៦-លោក	**ឯក**	**គាំត្រូឧត្តម**			

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៨៨.អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១២រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	**សុខ**	**ចិន្តា**	៧-លោក	**ទៀន**	**ពិសិដ្ឋ**
២-កញ្ញា	**ព្រំ**	**ចាវរិទ្ធ**	៨-លោក	**ហែន**	**វណ្ណជា**
៣-លោក	**គីម**	**សារ៉ាវុធ**	៩-កញ្ញា	**ចាន់**	**ស្រីមុំ**
៤-លោក	**ពុត**	**សារឿន**	១០-លោក	**សុខ**	**ចន្ទី**
៥-កញ្ញា	**ម៉ក**	**ម៉ាលីតា**	១១-លោក	**ស៊ីណា**	**វន្ថា**
៦-លោក	**ម៉ៅ**	**ដានី**	១២-លោក	**ផល**	**រដ្ឋា**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ ឧស. ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៤៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១២រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	**យាង**	**បញ្ញា**	៧-កញ្ញា	**ប៊ុល**	**ចាន់ណា**
២-កញ្ញា	**ង៉ៅ**	**តារា**	៨-លោក	**ដាន**	**ស៊ីថា**
៣-កញ្ញា	**ឈុន**	**សេរីរត្ន**	៩-កញ្ញា	**ដេង**	**កក្កដា**
៤-លោក	**ញឹម**	**វិបុល**	១០-លោក	**ម៉ែន**	**ចាន់រី**
៥-លោក	**ដាំ**	**ឧួច**	១១-លោក	**ណាក់**	**ពេជ្រពិជ័យ**
៦-លោក	**នេត**	**ខេមរា**	១២-លោក	**លាក**	**កល្យាណ**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៣
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១១រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	**អៀង**	**សុបញ្ញា**	៧-លោក	**សឿង**	**ភក្តី**
២-កញ្ញា	**ឆន**	**ឡាក់លី**	៨-កញ្ញា	**សុខ**	**អមរា**
៣-លោក	**នន់**	**វ៉ាន់ថន**	៩-កញ្ញា	**យិន**	**សុហាន**
៤-កញ្ញា	**វង្ស**	**ស្រីរ៉ុន**	១០-លោក	**លឹម**	**ឡាដាំង**
៥-លោក	**ជឿន**	**ប៊ុនរ័ត្ន**	១១-លោក	**ផាប់**	**ភា**
៦-លោក	**ទឹង**	**ធិដ្ឋាណា**			

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៦ . អនក្រ . បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១២រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	កែវ	សីលា	៧-លោក	ឯក	តារា
២-កញ្ញា	យ៉ុន	សុខគន្ធ	៨-លោក	ទឹម	វាសនា
៣-កញ្ញា	សូ	សំណាង	៩-លោក	យូ	រដ្ឋា
៤-កញ្ញា	កែវ	ស៊ីធួន	១០-លោក	ផាប់	ភាព
៥-លោក	ឃន	នរិន្ទ	១១-លោក	ជឹម	សុវណ្ណនាថ
៦-លោក	សំ	ខឿន	១២-លោក	នូ	សារុន

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩២ .អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនយុវជន ចំនួន១២រូប ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	ចាន់	ភក្តី	៧-លោក	ឡា	ខាន់ណា
២-កញ្ញា	យៀក	ស៊ីណា	៨-លោក	ឃុន	ខិតខំ
៣-កញ្ញា	ញឹក	ឡេវីន	៩-លោក	រីន	ពុទ្ធា
៤-កញ្ញា	ឈឹម	ចាន់ដេត	១០-លោក	ទីត	សុខៃ
៥-លោក	ហួត	ណារ៉ូរិទ្ធ	១១-លោក	ភាំង	ប៊ុនថន
៦-លោក	លី	វាសនា	១២-លោក	ផាន់	ភារម្យ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩៣ .អនក្រ .តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ៖

ត្រូវបានបំពាក់មេដាយ ការងារ តាមលំដាប់ថ្នាក់ ជូនដល់នាយនគរបាលជាតិ ក្នុងក្រុមការងារយេនឌ័រ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចំនួន ៦៣ នាក់ ដែលមានស្នាដៃល្អក្នុងការងារយេនឌ័ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ រយៈពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយ មាស ការងារ ៖

១- លោកជំទាវឧត្តមសេនីយ៍ឯក	យក់	សុខា	អត្តលេខ ០២២៥៧	អគ្គស្នងការរងនគរបាលជាតិ
២- លោកស្រីឧត្តមសេនីយ៍ទោ	ង៉ែត	ម៉ាលី	អត្តលេខ ០២១៦០	អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌
៣- លោកស្រីឧត្តមសេនីយ៍ទោ	ឌុច	ជាណា	អត្តលេខ ៣៣១១១	អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់
៤- លោកស្រីឧត្តមសេនីយ៍ត្រី	ឆយ	គឹមហ៊ាង	អត្តលេខ ០៨៩៩	អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ
៥- លោកឧត្តមសេនីយ៍ត្រី	ហុក	ថាវណ្ណ	អត្តលេខ ០៦៦៧	អនុប្រធាននាយកដ្ឋានបុគ្គលិក
៦- លោកស្រីវរសេនីយ៍ឯក	ហ៊ួត	យ៉ាន	អត្តលេខ ០៥៤៤១	អនុប្រធានអង្គភាពអន្តរាគមន៍
៧- លោកស្រីវរសេនីយ៍ឯក	មុំ	សាឃន	អត្តលេខ ០៥០១៧	អនុប្រធាននាយកដ្ឋានអង្គរក្ស
៨- លោកស្រីវរសេនីយ៍ឯក	អៃ	សុខខេម៉ា	អត្តលេខ ០២២៩១	អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ

៩- លោកស្រីវរសេនីយ៍ឯក	អៀង	វណ្ណៈ	អត្តលេខ ០៥៧៩៤	អនុប្រធាននាយកដ្ឋានសរុប-ផែនការ
១០- លោកស្រីវរសេនីយ៍ឯក	យូ	ប៉ូលីន	អត្តលេខ ០៥៧៥៣	ស្នងការរងហិរញ្ញកិច្ច និងកស្តុការ
១១- លោកស្រីវរសេនីយ៍ឯក	លឹម	សុវណ្ណា	អត្តលេខ ០៤៤៥៦	នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១២- លោកវរសេនីយ៍ឯក	លី	តុងហ៊ុយ	អត្តលេខ ០៧៩០	នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
១៣- លោកវរសេនីយ៍ទោ	តាន់	វណ្ណារ៉ាក់	អត្តលេខ ០២១៦២	ជំនួយការ អគ្គស្នងការរងនគរបាលជាតិ

ខ-មេបាយ ប្រាក់ ការខារ ៖

១- លោកស្រីឧត្តមសេនីយ៍ត្រី	សន	សុផល	អត្តលេខ ០៩៧៣៨	ស្នងការរង នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
២- លោកស្រីវរសេនីយ៍ឯក	ឈឹម	វណ្ណនី	អត្តលេខ ០២៥៣៤	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល
៣- លោកស្រីវរសេនីយ៍ឯក	សោម	សុខា	អត្តលេខ ០២៩៧៥	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
៤- លោកស្រីវរសេនីយ៍ឯក	សុខ	សំ	អត្តលេខ ០២៦៣១	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប
៥- លោកស្រីវរសេនីយ៍ឯក	អ៊ុក	សុខុម	អត្តលេខ ០១៧២៣	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៦- លោកស្រីវរសេនីយ៍ឯក	ប្រាក់	សៅនី	អត្តលេខ ០៩០២៤	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
៧- លោកស្រីវរសេនីយ៍ឯក	ឌី	សុជាតិ	អត្តលេខ ០៨១០១	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ
៨- លោកស្រីវរសេនីយ៍ឯក	យូ	ប៉ូលីវ៉ុជ	អត្តលេខ ១២១៩៤	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកោះកុង
៩- លោកស្រីវរសេនីយ៍ឯក	សេង	សេរីវង្ឍា	អត្តលេខ ០១៨៣៤	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកំពត
១០- លោកស្រីវរសេនីយ៍ឯក	ភ្លាន់	សុផល	អត្តលេខ ០៨១៨៤	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់
១១- លោកស្រីវរសេនីយ៍ឯក	ប៉ែន	កញ្ញា	អត្តលេខ ០៨៣៣១	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ
១២- លោកស្រីវរសេនីយ៍ឯក	ប៊ឹក	ផល្លា	អត្តលេខ ០១៨៨៦	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកែប
១៣- លោកស្រីវរសេនីយ៍ឯក	ព្រាប	សារី	អត្តលេខ ០៣២៨៦	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង
១៤- លោកស្រីវរសេនីយ៍ឯក	ប៊ី	សារិន	អត្តលេខ ០៣៤២៤	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង
១៥- លោកស្រីវរសេនីយ៍ឯក	គុជ	វត្តានី	អត្តលេខ ០៨៥៨៨	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ
១៦- លោកស្រីវរសេនីយ៍ឯក	សាត់	ម៉ី	អត្តលេខ ០៧៨៧៩	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ
១៧- លោកស្រីវរសេនីយ៍ឯក	ស្រី	ថាន់	អត្តលេខ ០៣០៨៣	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង
១៨- លោកស្រីវរសេនីយ៍ឯក	នៃ	សំណាង	អត្តលេខ ០៣៤២៦	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ
១៩- លោកស្រីវរសេនីយ៍ឯក	កែវ	ដារី	អត្តលេខ ០៦១៩១	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តរតនគិរី
២០- លោកស្រីវរសេនីយ៍ឯក	សាន់	សារឿន	អត្តលេខ ០២៨៤០	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន
២១- លោកស្រីវរសេនីយ៍ឯក	ណា	នាង	អត្តលេខ ៦៨២៤៩	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ
២២- លោកស្រីវរសេនីយ៍ឯក	ជិន	សុគន្ធា	អត្តលេខ ១០៦៤៨	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ
២៣- លោកស្រីវរសេនីយ៍ទោ	អៀម	វណ្ណី	អត្តលេខ ១១៤១៥	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
២៤- លោកស្រីវរសេនីយ៍ទោ	ហួន	គឹមហេង	អត្តលេខ ១២០៣២	ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី
២៥- លោកស្រីវរសេនីយ៍ទោ	ឈុន	មរកត	អត្តលេខ ០៣៣៦៦	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២៦- លោកស្រីវរសេនីយទោ	មាឃ	ផាន់នី	អត្តលេខ ០៥៣៦៣	នាយរងការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ
២៧- លោកស្រីវរសេនីយ៍ត្រី	តូច	ផល្លា	អត្តលេខ ១៩៣៣៣	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនគោក
២៨- លោកស្រីវរសេនីយ៍ត្រី	ហែម	ឬទ្ធី	អត្តលេខ ០៩៤៥៩	នាយរងការិយាល័យ នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង
២៩- លោកស្រីវរសេនីយ៍ត្រី	ប៉ុច	ជីតា	អត្តលេខ ០៥៩៥៧	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលការពារបេតិកភ័ណ្ឌ

៣០- លោកស្រីវរសេនីយ៍ត្រី	ឈឹម	គឹមសៅ	អត្តលេខ ១៦២២៨	អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្ដាលសន្តិសុខ
៣១- លោកវរសេនីយ៍ត្រី	រស់	ណារិទ្ធ	អត្តលេខ ៦០២៥២	ជំនួយការ អគ្គស្នងការរងនគរបាលជាតិ
៣២- លោកអនុសេនីយ៍ឯក	ប៉ែន	សុជាតិរតនៈ	អត្តលេខ ៦៦១៩២	ជំនួយការ អគ្គស្នងការរងនគរបាលជាតិ

គ-មេដាយ សិរីវឌ្ឍ ការងារ ៖

១- លោកស្រីវរសេនីយ៍ត្រី	ឡុក	សារុំ	អត្តលេខ ០៨៤៦១	នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
២- លោកស្រីវរសេនីយ៍ត្រី	ជឹម	រ៉ាលី	អត្តលេខ ០៩៩២៩	នាយផ្នែក នៃនាយកដ្ឋានអន្តោប្រវេសន៍
៣- លោកស្រីវរសេនីយ៍ត្រី	សុនច័ន្ទ	ភួងម៉ាឡា	អត្តលេខ ០៦១២៣	នាយផ្នែក នៃមន្ទីរប្រឆាំងការគ្រឿងញៀន
៤- លោកស្រីវរសេនីយ៍ត្រី	ជេន	សុគន្ធា	អត្តលេខ ០៦៣៥១	នាយផ្នែក នៃនាយកដ្ឋានប្រឆាំងភេរវកម្ម
៥- លោកស្រីអនុសេនីយ៍ឯក	ខូច	សុភាព	អត្តលេខ ០៧១៣០	នាយផ្នែក នៃនាយកដ្ឋាននគរបាលការពារ
៦- លោកស្រីអនុសេនីយ៍ឯក	ឈឹម	យ៉ាដាម៉ូនី	អត្តលេខ ១៣០២៧	នាយផ្នែក នៃនាយកដ្ឋានកិច្ចការបរទេស
៧- លោកស្រីអនុសេនីយ៍ឯក	អុល	វល័ក្ខ	អត្តលេខ ៥៤៦៦៤	នាយផ្នែក នៃនាយកដ្ឋានចារកម្ម
៨- លោកស្រីអនុសេនីយ៍ឯក	កាន់	វុទ្ធាមី	អត្តលេខ ០៦០១៤	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលអន្តរជាតិ
៩- លោកស្រីអនុសេនីយ៍ឯក	ទេព	សុគន្ធ	អត្តលេខ ០៦៦៨១	នាយរងផ្នែក នៃនាយកដ្ឋានរដ្ឋបាលទូទៅ
១០- លោកអនុសេនីយ៍ឯក	អែល	កំសាន្ត	អត្តលេខ ៥៤៧៥២	នាយរងផ្នែក នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
១១- លោកស្រីអនុសេនីយ៍ឯក	ម៉ៅ	សៅដា	អត្តលេខ ៣២១៤៩	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន
១២- លោកស្រីអនុសេនីយ៍ទោ	ហេង	រិទ្ធី	អត្តលេខ ៣២០១៣	នាយរងផ្នែក នៃនាយកដ្ឋានសណ្ដាប់ធ្នាប់
១៣- លោកស្រីអនុសេនីយ៍ទោ	សុខ	ស្រីមុំ	អត្តលេខ ៣០៨៤១	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
១៤- លោកស្រីអនុសេនីយ៍ទោ	ផៃ	សាវ៉ុន	អត្តលេខ ៣៧២១៧	នាយរងផ្នែក នៃអង្គភាពតម្រួតបទបញ្ជា
១៥- លោកស្រីអនុសេនីយ៍ទោ	សោម	វណ្ណៈរ៉ាត់ទីនី	អត្តលេខ ៣១៨២៤	មន្ត្រី នៃនាយកដ្ឋានបំភ័ន្តអក្ខរៈ
១៦- លោកស្រីអនុសេនីយ៍ត្រី	ប៊ុន	ស្រីពៅ	អត្តលេខ ៣៧០០១	នាយរងផ្នែក នៃនាយកដ្ឋានបច្ចេកទេសព្រំដែន
១៧- លោកស្រីអនុសេនីយ៍ត្រី	ទិត្យ	គឹមលន់	អត្តលេខ ៣៣០៦៣	មន្ត្រី នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៨- លោកស្រីព្រិន្ទបាលឯក	ប៉ុល	កូឡាប	អត្តលេខ ៣៧៨៣៦	នាយរងផ្នែក នៃនាយកដ្ឋានវិទ្យុទាក់ទង

មាត្រា ២ ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩៤ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅរាជធានីភ្នំពេញចំនួន ១៣៦ នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

ក- មេដាយមាសការងារ ៖

១-លោក **រ័ត្ន មូរី**	ប្រធានការិយាល័យសាលារាជធានីភ្នំពេញ
២-លោក **ឡេង ជាង**	ប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៣-លោក **ជាង សុត័ស្ស**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៤-លោក **ម៉ៅ ចន្ថា**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៥-លោក **តូច ពណ្ណរាយ**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៦-លោក **ម៉ន គឹមឈួន**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៧-លោក **សោម វ៉ាន់ដា**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៨-លោក **ឈាន ខុឌ្ឍី**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៩-លោក **ថៃ ស្រ៊ុន**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ

១០-លោកស្រី **ឱក គីមឌីណា**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
១១-លោក **ម៉េត មាសឥត្ថី**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
១២-លោក **ទួន មាសចំរើន**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
១៣-លោក **ព្រាប ពុទ្ធារ៉ា**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
១៤-លោក **អ៊ិន អាស្នា**	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
១៥-លោក **អេង សេតស៊ីម៉ា**	មន្ត្រីសាលារាជធានីភ្នំពេញ
១៦-លោក **គួយ ស៊ុយប៊ុន**	មន្ត្រីសាលារាជធានីភ្នំពេញ
១៧-លោកស្រី **ផាត ពិសី**	មន្ត្រីសាលារាជធានីភ្នំពេញ
១៨-លោកស្រី **គុំ ស៊ុនទូ**	មន្ត្រីសាលារាជធានីភ្នំពេញ
១៩-លោកស្រី **សុត លក្ខណា**	មន្ត្រីសាលារាជធានីភ្នំពេញ
២០-លោក **គង់ សុភ័ក្រ្ត**	មន្ត្រីសាលារាជធានីភ្នំពេញ
២១-លោកស្រី **ឡៅម ទិទ្ធិដិកា**	មន្ត្រីសាលារាជធានីភ្នំពេញ
២២-លោកស្រី **សុខ ម៉ារីនី**	មន្ត្រីសាលារាជធានីភ្នំពេញ
២៣-លោកស្រី **សេន គីមអេង**	មន្ត្រីសាលារាជធានីភ្នំពេញ
២៤-លោកស្រី **យង់ សីលា**	មន្ត្រីសាលារាជធានីភ្នំពេញ
២៥-លោក **ណៃ ស៊ីថា**	មន្ត្រីសាលារាជធានីភ្នំពេញ
២៦-លោកស្រី **ម៉ៃ រតនា**	មន្ត្រីសាលារាជធានីភ្នំពេញ
២៧-លោក **ម៉ៃ ចណ្ណារុំ**	មន្ត្រីសាលារាជធានីភ្នំពេញ
២៨-លោក **ម៉ុន រតនៈ**	មន្ត្រីសាលារាជធានីភ្នំពេញ
២៩-លោក **ផល សុភក្ស**	មន្ត្រីសាលារាជធានីភ្នំពេញ
៣០-លោកស្រី **លាប យុទ្ធថាច**	មន្ត្រីសាលារាជធានីភ្នំពេញ
៣១-លោកស្រី **ម៉ប់ ម៉ាណេត**	មន្ត្រីសាលារាជធានីភ្នំពេញ
៣២-លោក **ហ៊ួយ ទីរៈ**	មន្ត្រីសាលារាជធានីភ្នំពេញ
៣៣-លោក **សាន់ ម៉ុនណា**	មន្ត្រីសាលារាជធានីភ្នំពេញ
៣៤-លោក **ឈឿន ហ៊ីខេល**	មន្ត្រីសាលារាជធានីភ្នំពេញ
៣៥-លោកស្រី **មាស រតនី**	មន្ត្រីសាលារាជធានីភ្នំពេញ
៣៦-លោក **ម៉ុន ម៉ានិត**	មន្ត្រីសាលារាជធានីភ្នំពេញ
៣៧-លោកស្រី **សុខឡេង មុំរ៉ាទី**	មន្ត្រីសាលារាជធានីភ្នំពេញ
៣៨-លោក **រ័ត្ន បណ្ឌូល**	មន្ត្រីសាលារាជធានីភ្នំពេញ
៣៩-លោក **មា សុភាព**	សមាជិកក្រុមប្រឹក្សាខណ្ឌចំការមន រាជធានីភ្នំពេញ
៤០-លោក **ម៉ុក ពុទ្ធា**	នាយករដ្ឋបាលសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ
៤១-លោក **ចន្សៀ សៀងហាក់**	ប្រធានការិយាល័យសាលាខណ្ឌពោធិ៍សែនជ័យ
៤២-លោក **មុំ លីមហួរ**	អនុប្រធានការិយាល័យសាលាខណ្ឌ៧មករា
៤៣-លោកស្រី **ម៉ែន ធារី**	មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ
៤៤-លោក **ពៅ សំអុល**	មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ
៤៥-លោក **ទូច សារឹម**	មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ
៤៦-លោក **សែល ទូច**	មន្ត្រីសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ

៤៧-លោក ឆួន សុខុម	មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ
៤៨-លោកស្រី ខេង ផាត	មន្ត្រីសាលខណ្ឌដូនពេញ រាជធានីភ្នំពេញ
៤៩-លោក ឈឹម សុផល	មន្ត្រីសាលាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
៥០-លោក លី ណៃសៀន	មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
៥១-លោកស្រី សោម ផល្លី	មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
៥២-លោកស្រី កែវ សារី	មន្ត្រីសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
៥៣-លោក ម៉ៅ វណ្ណា	ស្មៀនសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ
៥៤-លោក ឡូយ សុវណ្ណា	ស្មៀនសង្កាត់អូឡាំពិក ខណ្ឌចំការមន

ខ- មេដាយប្រាក់ការងារ ៖

១-លោក ជុំ ម៉ុណ្ណារិន	ប្រធានការិយាល័យសាលារាជធានីភ្នំពេញ
២-លោក ឡៀម ស្ថាពរ	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៣-លោក នៅ ម៉ាត	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៤-លោក ទូច សីហា	អនុប្រធានការិយាល័យសាលារាជធានីភ្នំពេញ
៥-លោកស្រី គល់ លទ្ធិណា	មន្ត្រីសាលារាជធានីភ្នំពេញ
៦-លោក ពិន រដ្ឋា	មន្ត្រីសាលារាជធានីភ្នំពេញ
៧-លោក ម៉ម សុធារិទ្ធិ	មន្ត្រីសាលារាជធានីភ្នំពេញ
៨-លោកស្រី យឹម ម៉ានិត	មន្ត្រីសាលារាជធានីភ្នំពេញ
៩-លោកស្រី ហេង សោភ័ណ្ឌា	មន្ត្រីសាលារាជធានីភ្នំពេញ
១០-លោកស្រី យ៉េន ម៉ុនណាត	មន្ត្រីសាលារាជធានីភ្នំពេញ
១១-លោក សេង ហួផេង	មន្ត្រីសាលារាជធានីភ្នំពេញ
១២-លោកស្រី ឈាង តុលា	មន្ត្រីសាលារាជធានីភ្នំពេញ
១៣-លោកស្រី សយ សុធាវី	មន្ត្រីសាលារាជធានីភ្នំពេញ
១៤-លោក ឈឿន ហ្សូលី	មន្ត្រីសាលារាជធានីភ្នំពេញ
១៥-លោកស្រី យឹម មុនីដា	មន្ត្រីសាលារាជធានីភ្នំពេញ
១៦-លោក លឹម ម៉េងលី	មន្ត្រីសាលារាជធានីភ្នំពេញ
១៧-លោកស្រី ប្រាក់ ច័ន្ទណារ៉ា	មន្ត្រីសាលារាជធានីភ្នំពេញ
១៨-លោក សូ ម៉ូច	មន្ត្រីសាលារាជធានីភ្នំពេញ
១៩-លោក ឆេព សារឿន	មន្ត្រីសាលារាជធានីភ្នំពេញ
២០-លោក ញៀម ដា	មន្ត្រីសាលារាជធានីភ្នំពេញ
២១-លោក សំ ថន	មន្ត្រីសាលារាជធានីភ្នំពេញ
២២-លោក គឹម សុភារិន	មន្ត្រីសាលារាជធានីភ្នំពេញ
២៣-លោកស្រី ចន្ធ សុភាវត្តី	មន្ត្រីសាលារាជធានីភ្នំពេញ
២៤-លោកស្រី កុយ រដ្ឋា	មន្ត្រីសាលារាជធានីភ្នំពេញ
២៥-លោកស្រី សៀង ស្រីស្រស់	មន្ត្រីសាលារាជធានីភ្នំពេញ
២៦-លោក ឆួន រតនា	មន្ត្រីសាលារាជធានីភ្នំពេញ
២៧-លោក រាជ្យ សុខា	មន្ត្រីសាលារាជធានីភ្នំពេញ
២៨-លោក កែង ថា	នាយករងរដ្ឋបាលសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ

២៩-លោក **អ៊ុត សុភា**	អនុប្រធានការិយាល័យសាលាខណ្ឌសែនសុខ
៣០-លោក **ម៉ុក សុធិន**	អនុប្រធានការិយាល័យសាលាខណ្ឌដង្កោ
៣១-លោកស្រី **ឡុង សុខា**	អនុប្រធានការិយាល័យសាលាខណ្ឌចំការមន
៣២-លោក **រាជ កុសល**	អនុប្រធានការិយាល័យសាលាខណ្ឌឫស្សីកែវ
៣៣-លោកស្រី **សុខ សុផារ័ក្ស**	មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ
៣៤-លោក **សុខ មុន្នីឧត្តម**	មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ
៣៥-លោកស្រី **ហ៊ីង សាទី**	មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ
៣៦-លោកស្រី **យឹម ម៉ុណ្ណា**	មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ
៣៧-លោកស្រី **រស់ ធារី**	មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ
៣៨-លោក **ឈាន ណារ៉ា**	មន្ត្រីសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ
៣៩-លោក **យី ស៊ីម**	មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ
៤០-លោក **ឯក សុតិន**	មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ
៤១-លោក **ម៉ែន សុភា**	មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ
៤២-លោក **ឌួង យ៉ាម៉ៅ**	មន្ត្រីសាលាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
៤៣-លោក **អ៊ុក ចិន្តា**	មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
៤៤-លោក **ស្រេង គីមស្រ៊ន**	មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
៤៥-លោក **ហឿន ប្រសើរ**	មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
៤៦-លោក **នុត វណ្ណា**	ស្មៀនសង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
៤៧-លោក **ជុំ ឃឿន**	ស្មៀនសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
៤៨-លោកស្រី **ស៊ឹម ចិន្តា**	ស្មៀនសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
៤៩-លោកស្រី **ទ្រីន កេតនា**	ស្មៀនសង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ
៥០-លោកស្រី **ម៉ូ សត្យាផាណារី**	ស្មៀនសង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ
៥១-លោក **ហួត ហេង**	ស្មៀនសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ
៥២-លោក **ស៊ុយ ចំណាប់**	ស្មៀនសង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
៥៣-លោក **កង ដារ៉ាវុធ**	អនុប្រធានការិយាល័យ នៃពន្ធនាគាររាជធានីភ្នំពេញ

គ- មេដាយសំរិទ្ធការងារ ៖

១-លោក **គីន រិទ្ធី**	មន្ត្រីសាលារាជធានីភ្នំពេញ
២-លោក **ហ៊ឹម ម៉ានីឡា**	ប្រធានការិយាល័យសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ
៣-លោកស្រី **ពៅ ចាន់ហាន**	អនុប្រធានការិយាល័យសាលាខណ្ឌសែនសុខ
៤-លោក **ម៉ម់ សារ៉ែត**	អនុប្រធានការិយាល័យសាលាខណ្ឌ៧មករា
៥-លោក **អ៊ី សុវណ្ណារ៉ា**	មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ
៦-លោក **គង់ សារ៉ាវុធ**	មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ
៧-លោក **លី ថាត**	មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ
៨-លោក **ឌី សុផល**	មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ
៩-លោក **ហៀង គីមហឿន**	មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ
១០-លោក **ស៊ុយ ចាន់វណ្ណា**	មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ
១១-លោក **ឡេង ម៉ាសាទី**	មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ

១២-លោក **ផាន់ តុលា** មន្ត្រីសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ
១៣-លោក **លឹម ម៉េងឈួង** មន្ត្រីសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ
១៤-លោក **ចក់ ពៅ** មន្ត្រីសាលាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
១៥-លោកស្រី **គ្រួច សាឡឿន** មន្ត្រីសាលាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
១៦-លោកស្រី **ស៊ិន ពិសី** មន្ត្រីសាលាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
១៧-លោកស្រី **សាញ់ សាមត្ថី** មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
១៨-លោកស្រី **ម៊ុត ពិសី** មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
១៩-លោក **ទ្រាំ សាន** មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ
២០-លោក **ទេព ភាន់** មន្ត្រីសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
២១-លោកស្រី **មាស រចនា** ស្មៀនសង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
២២-លោក **ទ្រាំ ចាន់ថន** ស្មៀនសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
២៣-លោក **ទីវ ពគុណា** ស្មៀនសង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
២៤-លោក **ណុន ស៊ីណាត** ស្មៀនសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
២៥-លោក **យ៉ុង សុខារ៉ា** ស្មៀនសង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ
២៦-លោក **ប្រាំង សំអាត** ស្មៀនសង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
២៧-លោក **ហែម តុល** អនុប្រធានការិយាល័យ នៃពន្ធនាគាររាជធានីភ្នំពេញ
២៨-លោក **ឈឹម វណ្ណា** អនុប្រធានការិយាល័យ នៃពន្ធនាគាររាជធានីភ្នំពេញ
២៩-លោក **សុខ អាទិត្យ** អនុប្រធានការិយាល័យ នៃពន្ធនាគាររាជធានីភ្នំពេញ

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៥ . អនក្រ . បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១ ស្តីពីការ

កែសម្រួលមាត្រា៨ មាត្រា១០ មាត្រា១២ និងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

-តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ១១ រូប នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដូចមានរាយនាមខាងក្រោម៖

១-លោក **សយ រាសី**	ឱ្យបំពេញមុខងារជាប្រធានផ្នែកទីភ្នាក់ងារប្រតិបត្តិការពិសេស មានឋានៈស្មើ **អគ្គនាយករង**
២-លោក **មុយ ទួន**	ឱ្យបំពេញមុខងារជាប្រធានផ្នែកត្រួតពិនិត្យក្របខ័ណ្ឌ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៣-លោក **សៀត ទិចិត្រ**	ឱ្យបំពេញមុខងារជាប្រធានផ្នែករដ្ឋបាល បុគ្គលិក និងជំនួយការច្បាប់ មានឋានៈស្មើ**ប្រធាននាយកដ្ឋាន**
៤-លោក **ចន់ ម៉ុនធឿន**	ឱ្យបំពេញមុខងារជាប្រធានផ្នែកអភិវឌ្ឍធនធានមនុស្សមានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៥-កញ្ញា **ផ្លែក វិណែរត**	ឱ្យបំពេញមុខងារជាប្រធានផ្នែកទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៦-លោក **ប្រាក់ ប្រានីដ្ឋា**	ឱ្យបំពេញមុខងារជាប្រធានផ្នែកត្រួតពិនិត្យ និងវាយតម្លៃតាមវិស័យ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៧-លោក **លន គឹមហេង**	ឱ្យបំពេញមុខងារជាប្រធានផ្នែកវិចារណកម្មរចនាសម្ព័ន្ធ និងដំណើរការ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៨-លោក **ខួន សុភិត្យា**	ឱ្យបំពេញមុខងារជាប្រធានផ្នែកសេវាសាធារណៈ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៩-លោកស្រី **លឹម ភិត្យា**	ឱ្យបំពេញមុខងារជាប្រធានផ្នែកផែនការសកម្មភាពអភិបាលកិច្ចល្អ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
១០-លោកស្រី **អ៊ុក ទូច**	ឱ្យបំពេញមុខងារជាប្រធានផ្នែកតារាងទូទាត់បៀវត្ស មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
១១-លោក **អ៊ុក សុភាព**	ឱ្យបំពេញមុខងារជាប្រធានផ្នែកព័ត៌មាន និងផ្សព្វផ្សាយ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងសាមីមន្ត្រី ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោក **រិន រ៉ាឌុឌ** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោក **អ៊ុន ម៉ានីទុធ** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៩៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានឃើញព្រះរាជក្រមលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា ១: ប្តូរប្រភេទក្របខ័ណ្ឌលោក **តុប កក្កដា** ពីឋានន្តរស័ក្តិថ្នាក់ងាររដ្ឋបាលថ្នាក់លេខ ៦ ទៅក្រមការថ្នាក់លេខ ១៤នៃក្របខ័ណ្ឌមន្ត្រីក្រមការ នៅក្រសួងបរិស្ថាន ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩ .សសរ

សេចក្តីសម្រេច
ស្តីពី
ការជ្រើសរើសពលទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

ប្រការ១ : អនុញ្ញាតឲ្យក្រសួងការពារជាតិ ជ្រើសរើសពលទាហាន ចំនួន ២៤០០ (ពីរពាន់បួនរយ)នាក់ សម្រាប់បំពេញឲ្យបណ្តាកងឯកភាពមួយចំនួនដូចខាងក្រោម ។

- បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការដ្ឋាន ចំនួន ១០០ នាក់
- បញ្ជាការដ្ឋានកងទ័ពជើងទឹក អគ្គបញ្ជាការដ្ឋាន ចំនួន ៣០០ នាក់
- បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន ចំនួន ៣០០ នាក់
- បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន ចំនួន ៥០០ នាក់
- កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ចំនួន ៣០០ នាក់
- កងពលតូចអន្តរាគមន៍លេខ១១ កងទ័ពជើងគោក ចំនួន ៣០០ នាក់
- កងពលតូចអន្តរាគមន៍លេខ១៤ កងទ័ពជើងគោក ចំនួន ៣០០ នាក់
- បញ្ជាការដ្ឋានការពារអាកាស កងទ័ពជើងគោក ចំនួន ១០០ នាក់
- យោធភូមិភាគទី២ បញ្ជាការដ្ឋានកងទ័ពជើងគោក ចំនួន ២០០ នាក់

ប្រការ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៣២៣ ឧរថ.មសក.ប្រក

ប្រកាស
ស្តីពី
នីតិវិធី និងបែបបទនៃការចុះបញ្ជីមាត្រាសាស្ត្រ និងការផ្តល់អាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ .បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៩៩២ ឧរថ. អសម.ប្រក ចុះថ្ងៃទី១២ ខែ តុលា ឆ្នាំ ២០១២ ស្តីពីពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា
- បានឃើញប្រកាសលេខ ៨៥៧ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិវឌ្ឍន៍ និងសហប្រតិបត្តិការមាត្រាសាស្ត្រ
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣២៤ ឧរថ.ម.ម.ជ សជណ ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១១ ស្តីពីការអនុវត្តច្បាប់មាត្រាសាស្ត្រកម្ពុជា
- បានឃើញសេចក្តីជូនដំណឹងលេខ ២៣៦៤ ឧរថ.មស.សជណ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីមាត្រាសាស្ត្រ និងអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា
- ពិនិត្យតាមតម្រូវការចាំបាច់របស់ក្រសួង

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

សម្រេច

ប្រការ១ : ប្រកាសនេះ មានគោលបំណង បង្កើតយន្តការ និងវិធានការ ដើម្បីជំរុញវិស័យឯកជន និងសហគ្រាសសាធារណៈដែលធ្វើពាណិជ្ជកម្ម និងអាជីវកម្មពាក់ព័ន្ធទៅ នឹងវិស័យមាត្រាសាស្ត្រឲ្យអនុវត្តនីតិវិធីបទប្បញ្ញត្តិនានា នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

ប្រការ២ : វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមានដូចតទៅ ៖

មាត្រាសាស្ត្រ សំដៅដល់វិទ្យាសាស្ត្រ និងការគ្រប់គ្រងទម្ងន់ និងរង្វាស់រង្វាល់។

ឧបករណ៍មាត្រាសាស្ត្រ សំដៅដល់ឧបករណ៍ទម្ងន់និងរង្វាស់រង្វាល់ដែលបម្រើឲ្យវិស័យមាត្រាសាស្ត្រ។

ទំនិញផលិត សំដៅដល់ផលិតផលទំនិញដែលមិនចាំបាច់វេចខ្ចប់ នឹងអាចដឹកជញ្ជូន ចរាចរលក់ដោយគ្រាន់តែបញ្ជាក់បរិមាណសុទ្ធ និងដាក់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ។

ទំនិញវេចខ្ចប់ សំដៅដល់ផលិតផលទំនិញ ដែលបានដាក់រៀបចំជាស្រេចក្នុងសម្ភារៈវេចខ្ចប់តាមនីតិវិធីណាមួយដែលបរិមាណផលិតផល នៃទំនិញនោះត្រូវបានកំណត់ និងបានបញ្ជាក់លើស្លាកសញ្ញាហើយដែលគេមិនអាចផ្លាស់ប្តូរ ឬកែប្រែខុសពីភាពដើមឡើយ។

ព្យាសកម្ម សំដៅដល់វិធីសាស្ត្រ និងបទប្បញ្ញត្តិនៃការក្រិតខ្នាតឧបករណ៍មាត្រាសាស្ត្រ។

ត្រួតពិនិត្យផ្ទៀងផ្ទាត់ដំបូង សំដៅដល់ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រថ្មី ឬដែលបានជួសជុលរួច មុនពេលដាក់ឲ្យប្រើប្រាស់។

ការអនុម័តគំរូ សំដៅដល់ការអនុម័តលើគំរូដាក់លាក់ណាមួយនៃឧបករណ៍មាត្រាសាស្ត្រ សម្រាប់ដាក់ឲ្យប្រើប្រាស់បន្ទាប់ពីបានសាកល្បងឧបករណ៍មួយ ឬច្រើនស្របតាមការតម្រូវដែលបានកំណត់។

ពាណិជ្ជកម្ម សំដៅដល់ទំនាក់ទំនង ឬកិច្ចសន្យាកិច្ចព្រមព្រៀង ការលក់ ការទិញ យោងតាមមាត្រា១៩ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងរាប់បញ្ចូល ទាំងការវេចខ្ចប់ទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាជីវកម្ម សំដៅដល់ការប្រកបមុខរបរលើការផលិត ការនាំចូល ការដំឡើង ការប្រើប្រាស់ ការជួសជុល ការថែទាំ និងការតាំងលក់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ដែលទាក់ទងនឹងផ្នែកមាត្រាសាស្ត្រ។

ផលិតផល សំដៅដល់ឧបករណ៍មាត្រាសាស្ត្រទំនិញផលិត និងទំនិញវេចខ្ចប់ដែលទាក់ទងនឹងផ្នែកមាត្រាសាស្ត្រ

មន្ត្រីត្រួតពិនិត្យ សំដៅដល់មន្ត្រីមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

បុគ្គល សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គល។

ពាណិជ្ជនាម សំដៅដល់សញ្ញាសំគាល់សម្រាប់បញ្ជាក់លក្ខណៈខុសគ្នានៃបុគ្គលនីមួយៗ។

នាមឧបករណ៍ សំដៅដល់ឈ្មោះឧបករណ៍មាត្រាសាស្ត្រ។

នាយកដ្ឋានទទួលបន្ទុក សំដៅដល់នាយកដ្ឋានអភិវឌ្ឍន៍ និងសហប្រតិបត្តិការមាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) ។

វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ សំដៅដល់ការចុះឈ្មោះ ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម ឬអង្គភាពផ្សេងៗក្នុងបញ្ជីមាត្រាសាស្ត្រ ជាលាយលក្ខណ៍អក្សរដោយមជ្ឈមណ្ឌលមាត្រា

សាស្ត្រជាតិ(ម.ម.ជ)នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានសុពលភាព ១(មួយ)ឆ្នាំ សម្រាប់យកទៅប្រើប្រាស់ទៅតាមច្បាប់ដែលអាចប្រើបាន និងបញ្ជាក់ថា អង្គភាពសេដ្ឋកិច្ចខាងលើនេះ បានធ្វើពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ពាក់ព័ន្ធនឹងផ្នែកមាត្រាសាស្ត្រ ដូចមានទម្រង់កំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា សំដៅដល់សេវាសញ្ញាមាត្រាសាស្ត្រ ជាការធានាពីសុក្រឹតភាពត្រឹមត្រូវច្បាស់លាស់របស់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ដូចដែលបានកំណត់ក្នុងប្រកាសលេខ៩៩២ ឧរថ. អសម ប្រក. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា។

អាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា សំដៅដល់ការប្រគល់សិទ្ធិស្របច្បាប់ សម្រាប់អ្នកកាន់អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្មក្នុងការធ្វើពាណិជ្ជកម្ម អាជីវកម្ម សេវាកម្មទាក់ទងនឹងផ្នែកមាត្រាសាស្ត្រ ដែលអនុញ្ញាតដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងកំណត់សុពលភាព រយៈពេល **៣ (បី) ឆ្នាំ** ដូចមានទម្រង់កំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

ប្រការ៣ : វិសាលភាពនៃប្រកាសនេះគ្របដណ្តប់ទៅលើការចុះបញ្ជីមាត្រាសាស្ត្រ និងអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ចំពោះការផលិត ការនាំចូល ការដំឡើង ការប្រើប្រាស់ ការជួសជុល និងការលក់ ឬតាំងលក់នូវឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ដែលមានពាណិជ្ជនាម នាមឧបករណ៍ ការបញ្ជាក់អំពីខ្នាត សមត្ថភាព ត្រឹមត្រូវច្បាស់លាស់។

ប្រការ៤ : ការចុះបញ្ជីមាត្រាសាស្ត្រ និងការផ្តល់អាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ជាការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងបទប្បញ្ញត្តិនានា លើការគ្រប់គ្រងទិន្នន័យផ្នែកមាត្រាសាស្ត្រ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវចំពោះការផលិត ការនាំចូល ការដំឡើង ការប្រើប្រាស់ ការជួសជុល និងការតាំងលក់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ទំនិញវេចខ្ចប់ និងគ្រប់មធ្យោបាយបម្រើសេវាកម្មក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម និងវិស័យផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រតិបត្តិដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយមាននាយកដ្ឋានអភិវឌ្ឍន៍ និងសហប្រតិបត្តិការមាត្រាសាស្ត្រទទួលបន្ទុកជាសេនាធិការ។

ប្រការ៥ : អ្នកស្នើសុំចុះបញ្ជីមាត្រាសាស្ត្ររបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្មត្រូវដាក់ពាក្យស្នើសុំនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមលក្ខខណ្ឌចាំបាច់ដែលកំណត់ដូចខាងក្រោម ៖

- ពាក្យស្នើសុំចុះបញ្ជីមាត្រាសាស្ត្រ
- វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រសួងពាណិជ្ជកម្ម ឬប័ណ្ណប៉ាតង់
- តារាងរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រ ឬទំនិញផលិត ឬទំនិញវេចខ្ចប់ ដែលទាក់ទងនឹងផ្នែកមាត្រាសាស្ត្រ។

ប្រការ៦ : អ្នកស្នើសុំអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ត្រូវអញ្ជើញមន្ត្រីជំនាញមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យដល់ទីកន្លែងជាក់ស្តែង និង បំពេញបែបបទទៅតាមលក្ខខណ្ឌចាំបាច់ដែល កំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងភ្ជាប់មកជាមួយនូវរាល់ឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ
- វិញ្ញាបនបត្រអនុម័តគំរូ ឬវិញ្ញាបនបត្រព្យាសកម្ម ឬវិញ្ញាបនបត្រត្រួតពិនិត្យ-ផ្ទៀងផ្ទាត់
- លិខិតបញ្ជាក់បទដ្ឋានបច្ចេកទេស (specification) របស់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិតនិង ទំនិញវេចខ្ចប់
- លិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់(សម្រាប់អ្នកនាំចូល)
- អាជ្ញាប័ណ្ណផលិត ជួសជុល ឧបករណ៍មាត្រាសាស្ត្រ
- តារាងរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រ ឬទំនិញផលិត ឬទំនិញវេចខ្ចប់ ដែលទាក់ទងនឹងផ្នែក មាត្រាសាស្ត្រ។

ប្រការ៧ : ក្រោយពីបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦ អ្នកស្នើសុំត្រូវមកចុះកិច្ចព្រមព្រៀង ជាមួយមជ្ឈ-មណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីបញ្ជាក់អំពីលក្ខខណ្ឌ អាជ្ញាប័ណ្ណ ប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ជាមុនសិនទើបទទួលការផ្តល់អាជ្ញាប័ណ្ណ។

ប្រការ៨ : ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាដែលអ្នកកាន់អាជ្ញាប័ណ្ណទទួលបាន អាចប្រើក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម និងវិស័យផ្សេងទៀតដូចខាងក្រោម ៖

-បិទភ្ជាប់ ឬបោះពុម្ពពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា លើឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និង ទំនិញវេចខ្ចប់ក្នុងរបៀបមួយដែលងាយស្រួលមើលឃើញដោយអនុលោម ទៅតាមទំហំខ្នាត តូច ឬ ធំ បានដោយសមាមាត្រទៅនឹងគំរូ ដែលមានចែងក្នុងប្រកាសលេខ ៩៩២ ឧរថ.អសម. ប្រក ចុះ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា។

-ប្រើបានតែទៅលើឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ដែលមានអាជ្ញាប័ណ្ណប្រើ ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាតែប៉ុណ្ណោះ។

ប្រការ៩ : ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា មិនអាចបិទឬបោះពុម្ពទៅលើឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិតនិង ទំនិញវេចខ្ចប់ ដែលមានការផ្លាស់ប្តូរ ឬបន្ថែម ឬដែលពុំមែនជាកម្មសិទ្ធិរបស់ម្ចាស់អាជ្ញាប័ណ្ណឡើយ ទោះ ជាមានពាណិជ្ជនាម នាមឧបករណ៍ ខ្នាត ទម្ងន់ ចំណុះដូចគ្នាក៏ដោយ។ ក្នុងករណីនេះអ្នកគ្មានអាជ្ញាប័ណ្ណ ប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា និងអ្នកដែលមានអាជ្ញាប័ណ្ណហើយតែពង្រីក ឬផ្លាស់ប្តូរមុខផលិត ផល របស់ខ្លួនត្រូវទំនាក់ទំនងមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដើម្បីស្នើសុំអាជ្ញាប័ណ្ណជាថ្មី។

ប្រការ១០ : ការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា អ្នកកាន់កាប់អាជ្ញាប័ណ្ណ និងអ្នក ទទួលសិទ្ធិកាន់កាប់បន្តត្រូវមកទំនាក់ទំនងធ្វើការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាប័ណ្ណ នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រ ជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ១១ : ការបន្តអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាត្រូវបានកំណត់ដូចខាងក្រោម៖

- អ្នកកាន់អាជ្ញាប័ណ្ណបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនានា ដែលទាក់ទងទៅនឹងវិស័យមាត្រាសាស្ត្រ
- គោរព និងប្រតិបត្តិបានត្រឹមត្រូវ តាមខ្លឹមសារដែលមានចែងក្នុងកិច្ចព្រមព្រៀង
-អ្នកស្នើសុំត្រូវមកទំនាក់ទំនងស្នើសុំបន្តឲ្យបាន ៣០(សាមសិប)ថ្ងៃ មុនអាជ្ញាប័ណ្ណផុតសុពលភាព
-អាជ្ញាប័ណ្ណត្រូវបានផ្តល់ឲ្យក្នុងរយៈពេល ៩(ប្រាំបួន)ថ្ងៃ ក្រោយទទួលពាក្យស្នើសុំបន្ត។

ប្រការ១២ : អាជ្ញាប័ណ្ណត្រូវបានព្យួរទុកក្នុងរយៈពេលមួយមិនលើសពី ៣(បី)ខែ ក្នុងមួយលើក ប្រសិនបើ៖

- អ្នកកាន់អាជ្ញាប័ណ្ណមិនអនុវត្តតាមប្រការ៨ និងប្រការ៩ នៃប្រកាសនេះ
- ប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា តែធ្វើការផ្សព្វផ្សាយមិនបានត្រឹមត្រូវ ។

ប្រការ១៣ : អាជ្ញាប័ណ្ណត្រូវបានដកហូតនៅពេលដែលរកឃើញថា អ្នកកាន់អាជ្ញាប័ណ្ណ៖

- បានប្រព្រឹត្តកំហុសដូចគ្នាទៅនឹងកំហុសនាំឲ្យមានការព្យួរទុកលើកមុនដូចប្រការ១២នៃប្រកាសនេះ
- មិនគោរពតាមគំរូខ្នាតពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាដែលបានអនុញ្ញាតឲ្យប្រើ។

ប្រការ១៤ : ក្នុងករណីអាជ្ញាប័ណ្ណត្រូវផុតសុពលភាព ហើយមិនបាន មកបន្តទៅតាមនីតិវិធីដែលបានកំណត់ ឬក្នុងករណីត្រូវដកហូតអាជ្ញាប័ណ្ណ ហើយអ្នកកាន់អាជ្ញាប័ណ្ណ នៅតែបន្តប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា នឹងត្រូវព្រមាន និងពិន័យអន្តរការណ៍ ដោយមន្ត្រីត្រួតពិនិត្យទៅតាមមាត្រា ៤៣ ឬ មាត្រា៤៤ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

ប្រការ១៥ : រាល់ប្រកាសខ្លឹមសារនៃប្រកាស លេខ១៣៩ ឧរថ.មមជ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៦ : អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានអភិវឌ្ឍន៍ និងសហប្រតិបត្តិការមាត្រាសាស្ត្រ មានភារកិច្ចអនុវត្ត ក្នុងក្របខណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ។

ប្រការ១៧ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣

រដ្ឋមន្ត្រី

ស៊ុយ សែម

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋាន សេនាធិការ ក្រសួង ឧ.រ.ថ
- គ្រប់សហគ្រាសសាធារណៈ ចំណុះក្រសួង ឧ.រ.ថ
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
- ដូចប្រការ១៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១១៩ ប្រក. កសក

ប្រកាស
ស្តីពី
នីតិវិធីនៃការគ្រប់គ្រងដីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ៤១៥ប្រក.កសក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់នីតិវិធីសម្រាប់ការគ្រប់គ្រងជីកសិកម្ម ដែលត្រូវធ្វើពាណិជ្ជកម្មគ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២.-

ប្រកាសនេះមានគោលដៅធានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពនូវជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម ដែលមានប្រភពចេញពីប្រតិបត្តិការនៃការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយ ព្រមជាមួយការអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម ដើម្បីការពារនូវផលប្រយោជន៍របស់អ្នកប្រើប្រាស់ចុងក្រោយ ឬកសិករនៅក្នុងផលិតកម្មកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះជីកសិកម្មគ្រប់ប្រភេទ វត្ថុធាតុដើមសម្រាប់លាយផ្សំជីកសិកម្ម និងគ្រប់ប្រតិបត្តិការពាណិជ្ជកម្ម ព្រមទាំងសកម្មភាពក្រៅគោលបំណងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងជីកសិកម្មគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ការនាំចូលនាំចេញជីកសិកម្ម

ប្រការ ៤.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការនាំចូលនាំចេញជីកសិកម្មគ្រប់ប្រភេទ ក្នុងគោលបំណងធ្វើពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ប្រការ ៥.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជកម្ម សម្រាប់ការប្រើប្រាស់ជាក់លាក់ សម្រាប់តម្រូវការសាធារណៈឬឯកជន ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញ

សំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ តាមការកំណត់នៅក្នុងគំរូពាក្យស្នើសុំនាំចូលជីកសិកម្ម ក្រៅគោលបំណងពាណិជ្ជកម្ម។

ជីកសិកម្មដែលស្នើសុំនាំចូលសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវធ្វើការ ចុះបញ្ជីដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

ប្រការ ៦.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជ កម្ម ត្រូវបំពេញតាមលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ឯកសារយថាភូតបញ្ជាក់អត្តសញ្ញាណនៃអ្នកស្នើសុំ មានភាពសមស្របតាមគោលបំណង ប្រើប្រាស់ និងធានាភាពស្របច្បាប់
- បញ្ជាក់អំពីគោលបំណងប្រើប្រាស់ និងអំណះអំណាងហេតុផលនៃការប្រើប្រាស់ប្រភេទ ជីកសិកម្មដែលស្នើសុំ
- បញ្ជាក់បរិមាណជីកសិកម្មដែលត្រូវស្នើសុំនាំចូល ស្របតាមគោលបំណងប្រើប្រាស់
- បញ្ជាក់អត្តសញ្ញាណជីកសិកម្មដែលស្នើសុំ និងភ្ជាប់ឯកសារព្រឹត្តិបត្របច្ចេកទេសប្រភពដើម នៃជីកសិកម្មនោះជាចាំបាច់។

ប្រការ ៧.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលជីកសិកម្ម ដើម្បីធ្វើវិភាគបមាណីយ ធានា និងធ្វើការសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍ ក្នុងគោលបំណងធ្វើការចុះបញ្ជីប្រភេទ ជីកសិកម្មនោះ ត្រូវស្នើសុំលិខិតអនុញ្ញាតនាំចូលសំណាកជីកសិកម្មជាមុននៅនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់ គ្រាន់ តាមការកំណត់នៅក្នុងគំរូពាក្យស្នើសុំនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចផ្តល់លិខិតអនុញ្ញាតនាំចូលសំណាកជីកសិកម្ម នូវបរិមាណសមស្រប សម្រាប់តែធ្វើវិភាគបមាណីយធានានិងធ្វើការសាកល្បងជីវប្រសិទ្ធភាពលើទីវាល ពិសោធន៍ ដើម្បីបង្កើតទិន្នន័យជីវប្រសិទ្ធភាពតាមសំណើសុំការចុះបញ្ជី និងដោយផ្អែកតាមពិធីសារ បច្ចេកទេសសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្ម។

ប្រការ ៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម ត្រូវបង់កម្រៃ សេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំ កសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម អាចទទួលលទ្ធ ផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើពាក្យស្នើសុំរបស់ខ្លួន ក្នុង រយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនៅនាយកដ្ឋាន នីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្មមានសុពលភាពរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

ប្រការ ៩.-

ប្រតិបត្តិករនាំចូលជីកសិកម្ម ត្រូវធ្វើប្រតិវេទន៍ជាមុនក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីការនាំចូលមកដល់នៅក្នុងឃ្លាំងអចិន្ត្រៃយ៍របស់ប្រតិបត្តិករ ដើម្បីក្រសួងចាត់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យដើមគ្រា។

ការធ្វើប្រតិវេទន៍លើជីកសិកម្មនាំចេញ ត្រូវអនុវត្តនៅពេលប្រតិបត្តិករដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញជីកសិកម្ម។ រយៈពេលនៃការត្រួតពិនិត្យដើមគ្រាសម្រាប់ជីកសិកម្មនាំចេញ មិនត្រូវបានរាប់បញ្ចូលក្នុងដំណើរការពិនិត្យសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើការស្នើសុំនាំចេញជីកសិកម្មនោះឡើយ។

ជីកសិកម្មដែលធ្វើប្រតិវេទន៍នៅពេលធ្វើការនាំចូលឬធ្វើការនាំចេញ ត្រូវដកយកសំណាកដើម្បីធ្វើវិភាគបមាណីយធានា និងធ្វើការត្រួតពិនិត្យលើការអនុវត្តការតម្រូវបមាណីយនៅមុនពេលផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ ឬនៅមុនពេលធ្វើការនាំចេញ។

ប្រការ ១០.-

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី១នៃប្រកាសនេះ។

ជំពូកទី៣
ការលាយផ្សំ ការវេចខ្ចប់ជាថ្មី និងការធ្វើសន្និធិជីកសិកម្ម

ប្រការ ១១.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីនូវជីកសិកម្មគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មី នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ដំណើរការលាយផ្សំឬដំណើរការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវបានត្រួតពិនិត្យនិងវាយតម្លៃជាមុនដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការផ្តល់លិខិតអនុញ្ញាត។ របាយការណ៍នៃដំណើរការលាយផ្សំ ឬវេចខ្ចប់ជាថ្មី និងសមាសធាតុផ្សំជីកសិកម្ម ត្រូវមានភ្ជាប់ជាចាំបាច់ជាមួយសំណុំឯកសារនៃពាក្យស្នើសុំរបស់ប្រតិបត្តិករ។

ប្រការ ១២.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមិនរួមបញ្ចូលរយៈពេលនៃការត្រួតពិនិត្យនិងវាយតម្លៃលើដំណើរការលាយផ្សំឬវេចខ្ចប់ជាថ្មីនូវជីកសិកម្មនោះឡើយ។

ប្រការ ១៣.-

លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម មានសុពលភាពរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ក្នុងករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្មនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

ប្រការ ១៤.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវធ្វើប្រតិវេទន៍ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល២(ពីរ)លើកក្នុងមួយឆ្នាំ ឬនៅពេលស្នើសុំនាំចេញ អំពីផលិតផលជីកសិកម្មដែលចេញពីប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនៅឃ្លាំងសន្និធិអចិន្ត្រៃយ៍របស់ក្រុមហ៊ុន ដើម្បីក្រសួងចាត់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យលើការអនុវត្តការតម្រូវបមាណីយជីកសិកម្ម និងត្រូវដកយកសំណាកដើម្បីធ្វើវិភាគបមាណីយជានា នៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ ឬធ្វើការនាំចេញ។

ប្រការ ១៥.-

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

ប្រការ ១៦.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើសន្និធិជីកសិកម្មដើម្បីបម្រើឲ្យប្រតិបត្តិការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការផ្គត់ផ្គង់ចែកចាយ ក្នុងគោលបំណងពាណិជ្ជកម្ម ឬសម្រាប់ប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ឃ្លាំងសន្និធិជីកសិកម្ម ត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការចុះបញ្ជី។

ប្រការ ១៧.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឬចុះបញ្ជីជាថ្មី នូវឃ្លាំងសន្និធិជីកសិកម្មសម្រាប់គោលបំណងពាណិជ្ជកម្ម ឬក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវបង់កម្រៃសេវាកម្មចូលថវិកាជាតិជាមុន ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួនក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមិនរួមបញ្ចូលរយៈពេលនៃការត្រួតពិនិត្យនិងវាយតម្លៃលើប្រតិបត្តិការសន្និធិនិងទីតាំងឃ្លាំងសន្និធិឡើយ។

ប្រការ ១៨.-

វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិ មានសុពលភាពក្នុងរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្រ លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មី នូវវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិក្នុងរយៈពេល ៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ក្នុងករណីខកខានក្នុងការស្នើសុំជាថ្មី វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិនោះ ត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

ប្រការ ១៩.-

គំរូសំណុំបែបបទសម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៣នៃប្រកាសនេះ។

ជំពូកទី៤
ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូន

ប្រការ ២០.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់លិខិតអនុញ្ញាតនាំចូលនាំចេញ លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ និងលិខិតអនុញ្ញាតប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្មគ្រប់ប្រភេទ ដើម្បីធ្វើការផ្គត់ផ្គង់ចែកចាយដោយផ្ទាល់ដល់សាខារបស់ខ្លួន គ្រឹះស្ថានលក់ដុំលក់រាយ ឬដល់គោលដៅប្រើប្រាស់ផ្សេងទៀតដែលស្ថិតនៅតាមបណ្តាខេត្ត រាជធានីក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការផ្គត់ផ្គង់ចែកចាយបន្តនូវជីកសិកម្ម នៅតាមបណ្តាខេត្ត រាជធានីក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយទទួលយកជីកសិកម្មពីប្រភពដើមរបស់ក្រុមហ៊ុនដែលធ្វើការនាំចូល ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ដែលកាន់កាប់លិខិតអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវមានកិច្ចសន្យាធ្វើជាអ្នកផ្គត់ផ្គង់ចែកចាយរបស់ក្រុមហ៊ុនដើម និងត្រូវស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ប្រការ ២១.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួនក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ២២.-

លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មមានសុពលភាពរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ នៅមុនពេលផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

ប្រការ ២៣.-

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៤នៃប្រកាសនេះ។

ប្រការ ២៤.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការលក់ដុំលក់រាយជីកសិកម្មនៅក្នុងដែនរាជធានី ខេត្តនីមួយៗ ត្រូវស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្មនៅមន្ទីរកសិកម្មរាជធានី ខេត្តសាមី ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ក្នុងករណីក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តណាមួយដែលបានទទួលប្រតិភូកម្មអំណាច ដោយអនុលោមតាមប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការលក់ដុំលក់រាយជីកសិកម្ម ត្រូវស្នើសុំលិខិតអនុញ្ញាតនៅការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌសាមីនោះ។

ប្រការ ២៥.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់ប្រធានមន្ទីរកសិកម្មរាជធានី ខេត្តសាមី ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំដោយមន្ទីរកសិកម្ម។

ប្រការ ២៦.-

លិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្មមានសុពលភាពរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

ប្រការ ២៧.-

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៥នៃប្រកាសនេះ។

ប្រការ ២៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលដឹកជញ្ជូនជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានត្រួតពិនិត្យដោយមន្ត្រីអធិការកិច្ចជីកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការអនុវត្តបទបញ្ជាដូចខាងក្រោម៖

១- ត្រូវប្រើមធ្យោបាយដឹកជញ្ជូនឬមធ្យោបាយផ្ទុកជីកសិកម្ម ដោយធានាបាននូវសុវត្ថិភាពក្នុងការដឹកជញ្ជូន ជៀសវាងការផ្ទុះធ្លាយសម្ភារវេចខ្ចប់ឬមធ្យោបាយផ្ទុក និងរក្សាបាននូវបមាណីយគុណភាពដើមនៃជីកសិកម្ម។

២- សម្រាប់គោលបំណងនាំចូលនាំចេញ ត្រូវមានលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម ដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣- សម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយ ត្រូវមានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម និងឯកសារពាក់ព័ន្ធដែលកំណត់ច្បាស់លាស់នូវប្រភព ប្រភេទ បរិមាណនៃជីកសិកម្ម និងទីតាំងឬគ្រឹះស្ថានដែលទទួលយកការផ្គត់ផ្គង់ចែកចាយ។

ប្រការ ២៩.-

ត្រូវបានហាមឃាត់ការដឹកជញ្ជូនជីកសិកម្ម ដើម្បីចល័តលក់ដោយផ្ទាល់នៅគ្រប់ទីកន្លែងដល់អ្នកប្រើប្រាស់ចុងក្រោយដោយគ្មានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ ទោះក្នុងរូបភាពផ្សាយពាណិជ្ជកម្ម ការលក់បណ្តាក់ ការដោះដូរ ឬការធ្វើអំណោយក្តី ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

ប្រការ ៣០.-

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវគ្រប់គ្រងចរាចរណ៍លើទីផ្សារ និងការបោះបោលនូវជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ ព្រមទាំងសំណល់ជីកសិកម្មនិងសំបកវេចខ្ចប់ជីកសិកម្ម ដោយត្រូវដាក់បទបញ្ជាដល់ពាណិជ្ជករជីកសិកម្មឲ្យទទួលខុសត្រូវដូចខាងក្រោម៖

- ត្រូវធ្វើសន្និធិដាច់ដោយឡែកនូវជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ដោយដាក់សញ្ញាខ្វែង(×)សម្គាល់លើសំបកវេចខ្ចប់ឬលើមធ្យោបាយផ្ទុកនូវអក្សរពណ៌ក្រហម៖ "ជីកសិកម្មខូចគុណភាព" ឬ "ជីកសិកម្មក្រៅបមាណីយ" ឬ "ជីកសិកម្មហួសសុពលភាពប្រើប្រាស់"
- ត្រូវកត់ត្រាព័ត៌មានអំពីជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ នៅក្នុងសៀវភៅកំណត់ត្រាពាណិជ្ជកម្មរបស់ខ្លួន និងត្រូវរាយការណ៍ជូនមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីស្នើសុំវិធានការបច្ចេកទេស។

ប្រការ ៣១.-

ត្រូវហាមឃាត់ការធ្វើពាណិជ្ជកម្មគ្រប់រូបភាព ឬចរាចរណ៍លើទីផ្សារ ការបោះចោលក្នុងទីសាធារណៈ ឬទីកន្លែងផ្សេងទៀត នូវជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ឬជីកសិកម្មហួសសុពលភាពប្រើប្រាស់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់ជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ឬជីកសិកម្មហួសសុពលភាពប្រើប្រាស់ អាចស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីលក់សម្រាប់ឲ្យតែចំពោះរោងចក្រផលិតលាយជីកសិកម្ម សម្រាប់ការប្រើប្រាស់ពិសេស កសិដ្ឋានស្រាវជ្រាវ ឬវិទ្យាស្ថានស្រាវជ្រាវរបស់រដ្ឋ។

ប្រការ ៣២.-

ជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ ជីកសិកម្មក្លែងបមាណីយ ជីកសិកម្មលាយផ្សំដោយគ្មានមូលដ្ឋានបច្ចេកទេស ជីកសិកម្មមានប្រភពដើមល្មើសច្បាប់ ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មគ្រប់រូបភាព ឬធ្វើចរាចរណ៍លើទីផ្សារដោយល្មើសច្បាប់ ត្រូវឃាត់ទុកជាបណ្ដោះអាសន្នដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដោះស្រាយតាមនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

ជំពូកទី៥
ការផ្សាយពាណិជ្ជកម្មជីកសិកម្ម

ប្រការ ៣៣.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការផ្សាយពាណិជ្ជកម្មជីកសិកម្ម ត្រូវស្នើសុំការចុះបញ្ជីប្រភេទជីកសិកម្មនោះជាមុន ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

អត្ថបទផ្សព្វផ្សាយ ឯកសារបោះពុម្ព រូបភាពសោតទស្សន៍ បទបង្ហាញ មេរៀនណែនាំបច្ចេកទេសសម្រាប់សិក្ខាសាលាផ្សព្វផ្សាយ ឯកសារបច្ចេកទេសសម្រាប់ពិសោធន៍លើស្រែបង្ហាញ ឬលើទីវាលពិសោធន៍ ឬឯកសារផ្សេងទៀតសម្រាប់ការផ្សាយពាណិជ្ជកម្មជីកសិកម្មគ្រប់ប្រភេទ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ ៣៤.-

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវដាក់ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្មជីកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងរយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ នៅមុនកាលបរិច្ឆេទអនុវត្តការផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្ម។

ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្មជីកសិកម្ម ត្រូវភ្ជាប់ជាមួយនូវកម្មវិធីផ្សព្វផ្សាយប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលបញ្ជាក់នូវកាលបរិច្ឆេទនិងទីកន្លែងដែលត្រូវធ្វើការផ្សព្វផ្សាយ ការផ្សាយពាណិជ្ជកម្ម សិក្ខាសាលា ឬការធ្វើស្រែបង្ហាញ។ល។ រួមជាមួយអត្ថបទ ឬឯកសារបច្ចេកទេសដែលត្រូវប្រើប្រាស់ក្នុងការផ្សព្វផ្សាយ ដើម្បីអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការពិនិត្យ សិក្សា ឬធ្វើការកែតម្រូវតាមការចាំបាច់ ស្របតាមទិដ្ឋភាពបច្ចេកទេស។

ប្រការ ៣៥.-

អត្ថបទផ្សាយពាណិជ្ជកម្មជីកសិកម្មត្រូវមានខ្លឹមសារបច្ចេកទេសស្របតាមខ្លឹមសារបច្ចេកទេសដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវអនុលោមតាមព័ត៌មានឬទិន្នន័យដែលកំណត់ក្នុងស្លាកសញ្ញាព័ត៌មាន ឬតាមឯកសារបច្ចេកទេសនៃផលិតផលជីកសិកម្មដែលបានភ្ជាប់ និងបានអះអាងនៅក្នុងពេលធ្វើការចុះបញ្ជី។

អត្ថបទផ្សាយពាណិជ្ជកម្មជីកសិកម្មអាចអធិប្បាយក្នុងក្របខ័ណ្ឌដូចខាងក្រោម៖

- អត្តសញ្ញាណប្រភេទជីកសិកម្មរួមមាន ឈ្មោះពាណិជ្ជកម្ម ពាណិជ្ជសញ្ញា ឈ្មោះសារធាតុចិញ្ចឹម និងទម្រង់រូបសាស្ត្រ
- អត្តសញ្ញាណក្រុមហ៊ុនកាន់កាប់បញ្ជិកា លេខបញ្ជិកា ប្រទេសនិងក្រុមហ៊ុនប្រភពដើមនៃការលាយផ្សំ ការនាំចូល ការផ្គត់ផ្គង់ចែកចាយ
- របៀបប្រើប្រាស់រួមមាន ប្រភេទដំណាំគោលដៅ តំបន់ដាំដុះ បរិមាណ ពេលវេលាប្រើប្រាស់ ចំនួនលើកប្រើប្រាស់
- ប្រសិទ្ធភាពរបស់ផលិតផលជីកសិកម្មរួមមាន កំណើនទិន្នផល រយៈពេល និងរូបមន្តប្រើប្រាស់ជីកសិកម្មដែលផ្តល់កំណើនទិន្នផល
- ណែនាំអតិថិជនឲ្យអានសេចក្តីណែនាំនៅក្នុងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ មុននឹងធ្វើការប្រើប្រាស់។

ប្រការ ៣៦.-

ការផ្សាយពាណិជ្ជកម្មជីកសិកម្មត្រូវគោរពតាមវិធាន បទជៀសវាង និងបទហាមឃាត់សម្រាប់ការផ្សាយពាណិជ្ជកម្មជីកសិកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ប្រការ ៣៧.-

បន្ទាប់ពីបានទទួលសេចក្តីយល់ព្រមលើអត្ថបទផ្សព្វផ្សាយឬអត្ថបទផ្សាយពាណិជ្ជកម្មជីកសិកម្មរួចហើយ រូបវន្តបុគ្គលឬនីតិបុគ្គល មានសិទ្ធិធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងអនុវត្តកម្មវិធីផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្មផលិតផលជីកសិកម្មរបស់ខ្លួននៅរាជធានី ខេត្ត ដោយត្រូវជូនព័ត៌មានដល់មន្ទីរកសិកម្មសាមី ដើម្បីស្នើសុំកិច្ចសហការ។

ជំពូកទី៦
វិធានរួមនិងភាគពូកិច្ចពាណិជ្ជករជីកសិកម្ម

ប្រការ ៣៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រនៅក្នុងប្រតិបត្តិការពាណិជ្ជកម្ម ជីកសិកម្មគ្រប់រូបភាព ត្រូវបំពេញលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ត្រូវបំពេញសំណុំបែបបទស្នើសុំឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ស្របតាមការតម្រូវនៅក្នុងគំរូពាក្យស្នើសុំ
- ត្រូវមានសមត្ថភាពក្នុងការធ្វើប្រតិបត្តិការដែលពាក់ព័ន្ធនឹងការស្នើសុំរបស់ខ្លួន ដោយអនុលោមតាមរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តរបស់ប្រតិបត្តិករនៅក្នុងឆ្នាំកន្លងមក
- ត្រូវអនុវត្តកិច្ចប្រតិបត្តិល្អក្នុងការអនុវត្តច្បាប់ ការអនុវត្តការតម្រូវបមាណីយ បទបញ្ញា និងនីតិវិធីផ្សេងទៀត នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្មរបស់ខ្លួន
- មិនធ្លាប់បានទទួលទណ្ឌកម្មព្យួរឬដកហូតលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ ឬធ្លាប់បានទទួលទោសព្រហ្មទណ្ឌណាមួយនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្ម នៅក្នុងរយៈពេល២(ពីរ) ឆ្នាំចុងក្រោយ នៅមុនពេលស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រថ្មី។

ប្រការ ៣៩.-

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនាំចូលនាំចេញ លាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ឬធ្វើការផ្គត់ផ្គង់ ចែកចាយជីកសិកម្មគ្រប់ប្រភេទ ត្រូវដាក់តាំងបង្ហាញនៅក្នុងគ្រឹះស្ថានរបស់ខ្លួននូវលិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រដែលពាក់ព័ន្ធ និងត្រូវតម្កល់ឯកសារវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទជីកសិកម្មដែល កំពុងធ្វើប្រតិបត្តិការពាណិជ្ជកម្ម។

ពាណិជ្ជករលក់ដុំលក់រាយជីកសិកម្មត្រូវតាំងបង្ហាញក្នុងគ្រឹះស្ថានរបស់ខ្លួននូវលិខិតអនុញ្ញាត លក់ដុំលក់រាយ និងត្រូវតម្កល់ឯកសារវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទជីកសិកម្ម ឬបញ្ជីជីកសិកម្ម ដែលមានបញ្ជាក់លេខបញ្ជិកា។

ប្រការ ៤០.-

គ្រប់គ្រឹះស្ថានដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្ម ត្រូវមានសៀវភៅកំណត់ត្រាពាណិជ្ជកម្មតាមគំរូរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវចុះក្នុងសៀវភៅនោះ អំពីប្រភេទ យថាប្រភេទ បរិមាណជីកសិកម្មដែលធ្វើពាណិជ្ជកម្មប្រចាំឆ្នាំ និងកំណត់ត្រាព័ត៌មានចាំបាច់ផ្សេងទៀត។

ពាណិជ្ជករជីកសិកម្មត្រូវរាយការណ៍ ឬផ្តល់ព័ត៌មានជូនមន្ត្រីឬអង្គភាពកសិកម្មមានសមត្ថកិច្ច នៅក្នុងមូលដ្ឋានសាមី ក្នុងករណីសង្ស័យចំពោះអ្នកទិញជីកសិកម្មណាមួយយកទៅកែច្នៃឬផលិតជា គ្រឿងផ្ទុះក្រៅគោលបំណងកសិកម្ម ដែលអាចបង្កផលប៉ះពាល់ដល់សន្តិសុខជាតិ។

ប្រការ ៤១.-

ពាណិជ្ជករជីកសិកម្មដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មគ្រប់រូបភាព ត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវរក្សាសៀវភៅកំណត់ត្រាពាណិជ្ជកម្ម ឯកសារសក្ខីបត្រ វិក្កយបត្រ និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួននៅក្នុងរយៈពេលយ៉ាងតិច២(ពីរ)ឆ្នាំក្រោយប្រតិបត្តិការទាំងនោះបានបញ្ចប់

- ត្រូវគ្រប់គ្រងជីកសិកម្មដែលធ្វើសន្និធិសម្រាប់លក់ឲ្យបានសមស្របតាមលក្ខណបច្ចេកទេស និងធានាឲ្យឃ្លាំងសន្និធិជីកសិកម្មមានសុវត្ថិភាព ដោយត្រូវអនុវត្តការតម្រូវបមាណីយសម្រាប់ការធ្វើសន្និធិឬសម្រាប់ការដាក់តាំងលក់ជីកសិកម្ម

- ត្រូវបំពាក់ស្លាកសញ្ញាសុវត្ថិភាព ឧបករណ៍ការពារសុវត្ថិភាព ឧបករណ៍លាងសម្អាត សម្ភារអនាម័យ សម្ភារលុបបំបាត់ការលេចជ្រាប ប្រព័ន្ធការពារអគ្គីភ័យ និងប្រព័ន្ធការពារសុវត្ថិភាពផ្សេងទៀតនៅក្នុងគ្រឹះស្ថានធ្វើប្រតិបត្តិការរបស់ខ្លួន

- ត្រូវមានមធ្យោបាយសម្រាប់ផ្ទុកឬសន្និធិជីកសិកម្មដែលធានាមិនឆ្លុះឆ្លាយ មិនលេចជ្រាប ឬបាត់បង់គុណភាពនៅក្នុងការធ្វើសន្និធិ ការដឹកជញ្ជូន ការលើកដាក់ ឬក្នុងប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន

- ត្រូវអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីវិធានសុវត្ថិភាពក្នុងគ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធ និងបំពាក់ឧបករណ៍ការពារសុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការដោយផ្ទាល់

- ត្រូវកំណត់និងអនុវត្តបទដ្ឋានបច្ចេកទេសសម្រាប់ប្រើប្រាស់និងថែទាំឧបករណ៍ដែលប្រើប្រាស់ជាមួយជីកសិកម្ម និងឧបករណ៍ការពារសុវត្ថិភាព

- ត្រូវអនុវត្តកម្មវិធីត្រួតពិនិត្យនិងថែទាំសុខភាពជាប្រចាំដល់បុគ្គលិកប្រតិបត្តិការផ្ទាល់ជាមួយជីកសិកម្ម។

ប្រការ ៤២.-

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនាំចូល លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវជីកសិកម្ម អាចធ្វើការផ្គត់ផ្គង់ចែកចាយជីកសិកម្មចំពោះតែគ្រឹះស្ថានលក់ដុំលក់រាយឬសាខាចំណុះរបស់ខ្លួន ដែលកាន់កាប់លិខិតអនុញ្ញាតលក់ដុំលក់រាយស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនិងនីតិវិធីនៃប្រកាសនេះប៉ុណ្ណោះ។

ក្រុមហ៊ុនដែលធ្វើការផ្គត់ផ្គង់ចែកចាយ ឬផ្គត់ផ្គង់ចែកចាយបន្តនូវជីកសិកម្ម ត្រូវទទួលខុសត្រូវលើប្រតិបត្តិការពាណិជ្ជកម្មរបស់សាខាខ្លួនឬគ្រឹះស្ថានលក់ដុំលក់រាយទាំងឡាយណា ដែលបានចុះកិច្ចសន្យានិងទទួលយកការផ្គត់ផ្គង់ចែកចាយជីកសិកម្មរបស់ខ្លួន។

ក្រុមហ៊ុនដែលផ្គត់ផ្គង់ចែកចាយបន្ត គ្រឹះស្ថានលក់ដុំលក់រាយ និងកសិដ្ឋានដែលកាន់កាប់និងប្រើប្រាស់ជីកសិកម្ម ត្រូវទទួលយកការផ្គត់ផ្គង់ចែកចាយ ឬត្រូវទិញចូលសម្រាប់បម្រើប្រតិបត្តិការរបស់ខ្លួននូវជីកសិកម្មដែលមានប្រភពស្របច្បាប់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងនីតិវិធីនៃប្រកាសនេះ។

ប្រការ ៤៣.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាជីកសិកម្មគ្រប់ប្រភេទ មានកាតព្វកិច្ចធ្វើការសាកល្បងជីវប្រសិទ្ធភាពលើផលិតផលជីកសិកម្មរបស់ខ្លួនឡើងវិញ នៅក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំម្តង គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកាដំបូង ដោយអនុលោមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម។

ប្រការ ៤៤.-

ពាណិជ្ជករដែលធ្វើការផ្គត់ផ្គង់ចែកចាយ ឬធ្វើការលក់ដុំលក់រាយជីកសិកម្ម ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈជាមុន ដើម្បីបំពេញបុរេលក្ខខណ្ឌសម្រាប់ការស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ ឬលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម។

ពាណិជ្ជករដែលធ្វើការផ្គត់ផ្គង់ចែកចាយបន្ត ឬធ្វើការលក់ដុំលក់រាយជីកសិកម្ម ត្រូវដាក់ពាក្យស្នើសុំឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់ការធ្វើប្រតិបត្តិការរបស់ខ្លួន នៅមន្ទីរកសិកម្មរាជធានី ខេត្តសាមី។

ប្រការ ៤៥.-

មន្ទីរកសិកម្មរាជធានី ខេត្ត ដោយសហការនិងសម្របសម្រួលជាមួយនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចរៀបចំកម្មវិធី លើកគម្រោងបើកវគ្គ និងផ្តល់សេវាកម្មក្នុងការអនុវត្តកម្មវិធីអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់ការធ្វើពាណិជ្ជកម្មជីកសិកម្ម នៅតាមរាជធានី ខេត្តសាមី។

គោលការណ៍ណែនាំសម្រាប់ដំណើរការវគ្គអប់រំនិងកម្មវិធីអប់រំសមត្ថភាពវិជ្ជាជីវៈ សម្រាប់ការធ្វើពាណិជ្ជកម្មជីកសិកម្ម ត្រូវកំណត់ដោយនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ ៤៦.-

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនាំចូលនាំចេញ លាយផ្សំ និងវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវមានបុគ្គលិកបច្ចេកទេសប្រចាំការមួយរូបឬច្រើនរូប ដើម្បីទទួលខុសត្រូវជាអចិន្ត្រៃយ៍លើក្របខ័ណ្ឌបច្ចេកទេសក្នុងប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន និងត្រូវមានការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈដោយ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធី នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

ក្រុមហ៊ុនដែលស្នើសុំធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន នូវវិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកបច្ចេកទេសប្រចាំការ។ ក្រុមហ៊ុនត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីមានការបញ្ឈប់ ឬផ្លាស់ប្តូរបុគ្គលិកបច្ចេកទេស ដើម្បីស្នើសុំការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកថ្មី។

ការស្នើសុំការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកបច្ចេកទេសប្រចាំការ និងការស្នើសុំឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់អ្នកផ្គត់ផ្គង់ចែកចាយបន្ត អ្នកលក់ដុំលក់រាយជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

ជំពូកទី៧
ទោសប្បញ្ញត្តិ

ប្រការ ៤៧.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្មគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវចំពោះជីកសិកម្មដែលដាក់តាំងលក់ឬធ្វើសន្និធិសម្រាប់លក់នៅក្នុងគ្រឹះស្ថានពាណិជ្ជកម្មឬឃ្លាំងសន្និធិរបស់ខ្លួន ដោយត្រូវគោរពនិងអនុវត្តតាមបទប្បញ្ញត្តិ និងបទហាមឃាត់ក្នុងសកម្មភាពពាណិជ្ជកម្មជីកសិកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងត្រូវធ្វើសហការ បង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាពអប់រំណែនាំ ត្រួតពិនិត្យនិងអនុវត្តច្បាប់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ៤៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសឬមិនគោរពតាមនីតិវិធីនិងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

ជំពូកទី៨
អវសានប្បញ្ញត្តិ

ប្រការ ៤៩.-

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៥០.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្មរាជធានីខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៣

រដ្ឋមន្ត្រី

ជ័ន្ទ-សារុន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ៥០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ពន្ធទី១ នៃប្រកាសលេខ......១១៩............ប្រក.កសក ចុះថ្ងៃទី..១១..ខែ.[illegible].ឆ្នាំ២០១៣
ស្តីពី "**នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម**"

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម

ក-គំរូពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្មក្នុងគោលបំណងពាណិជ្ជកម្ម

I-**ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ** (General Information on the Applicant)	
១-ឈ្មោះអ្នកស្នើសុំ៖	
២-សញ្ជាតិ៖ អាយុ៖ ភេទ ៖	
៣-អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ៖ ផុតកំណត់ថ្ងៃទី៖	
៤-ក្រុមហ៊ុនឬនីតិបុគ្គលឯកជន៖ "គូសក្នុងប្រអប់"	
☐ នាំចូលនាំចេញ ☐ ផ្គត់ផ្គង់ចែកចាយ ☐ សហគមន៍កសិកម្ម ☐ លាយផ្សំ ☐ វេចខ្ចប់ជាថ្មី ☐ នីតិបុគ្គលឯកជនផ្សេងទៀត៖	
៥-អាសយដ្ឋាននៅកម្ពុជា៖	
ទូរសព្ទឬទូរសារ៖	
គេហទំព័រ៖	
៦-ចុះបញ្ជីពាណិជ្ជកម្ម៖ ចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត៖	
៧-ឃ្លាំងសន្និធិ	
លេខចុះបញ្ជី និងអាសយដ្ឋាន	
៨-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ "បើសិនជាមាន"	
៩-អត្តសញ្ញាណនៃប្រភពដើមលាយផ្សំឬផ្គត់ផ្គង់ចែកចាយ	
ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនប្រភពដើមផ្គត់ផ្គង់ចែកចាយ	
ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនប្រភពដើមលាយផ្សំ	

II-**គោលបំណងនៃការស្នើសុំ** (Purpose and state of application) "គូសក្នុងប្រអប់"	
☐ ការនាំចូល ☐ ការនាំចេញ ☐ ការផ្គត់ផ្គង់ចែកចាយ	☐ ការផ្ទេរសិទ្ធិលើលិខិតអនុញ្ញាត ☐ គោលបំណងពាណិជ្ជកម្មផ្សេងទៀត

III-**មធ្យោបាយដឹកជញ្ជូន កំពង់ផែ ឬមាត់ច្រកដែលនាំចូលនាំចេញ** (Mean of transport, port, or border entry to be imported-exported) "គូសក្នុងប្រអប់"	
មធ្យោបាយដឹកជញ្ជូន ៖ ☐ រថយន្ត ☐ នាវា ☐ យន្តហោះ ☐ មធ្យោបាយផ្សេងទៀត៖....................................	**កំពង់ផែឬមាត់ច្រក ៖** ☐ កំពង់ផែ... .... ☐ មាត់ច្រក... ....

IV-**យថាប្រភេទនិងបរិមាណជីកសិកម្មដែលស្នើសុំការនាំចូលនាំចេញ** (Specification & quantity of fertilizers to be imported/exported) ☐ មានភ្ជាប់ CD ឬបញ្ជីដោយឡែក (បើសិនជាច្រើន)

ល.រ No	យថាប្រភេទជីកសិកម្ម Specification	ឈ្មោះពាណិជ្ជកម្ម Trade name	លេខបញ្ជិកា Registration N⁰	បរិមាណស្នើនាំចូលនាំចេញ Quantity to be imported/exported	ក្រុមហ៊ុន/ប្រទេសប្រភពដើម Company/Country of origin
១					
២					
៣					
៤					
៥					
៦					
៧					
៨					
៩					
១០					
សរុបត្រឹមចំនួន៖....................មុខ បរិមាណ៖..............................					

𝒜

V-**បញ្ជីឯកសារត្រូវភ្ជាប់ជាមួយ** (List of documents enclosed)	
១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ប័ណ្ណប៉ាតង់ ឬប័ណ្ណបង់ពន្ធលើផលរបរ(ITR)នៃឆ្នាំចុងក្រោយ ឬឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត។	០១ច្បាប់
២- ឯកសារឬកិច្ចសន្យាបញ្ជាក់ការផ្គត់ផ្គង់របស់ក្រុមហ៊ុនប្រភពដើម។	០១ច្បាប់
៣- របាយការណ៍ត្រួតពិនិត្យជើមគ្រានៅពេលស្នើសុំនាំចេញជីកសិកម្ម (ករណីនាំចេញ)។	០១ច្បាប់
៤- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មតាមយថាប្រភេទនីមួយៗ ដែលត្រូវស្នើសុំនាំចូលនាំចេញ។	០១ច្បាប់
៥- សំបកវេចខ្ចប់ជីកសិកម្មតាមប្រភេទនីមួយៗដែលមានស្លាកសញ្ញាព័ត៌មានឬបរិយាយប័ណ្ណសម្រាប់ការណែនាំជាភាសាខ្មែរដែលបានយល់ព្រមនៅពេលធ្វើការចុះបញ្ជី។	០១ច្បាប់
៦- លិខិតបញ្ជាក់របស់ក្រុមហ៊ុនអំពីអត្តសញ្ញាណបុគ្គលិកបច្ចេកទេសប្រចាំការគ្រឹះស្ថាននាំចូលនាំចេញរបស់ខ្លួន និងដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។	០១ច្បាប់
៧- របាយការណ៍អំពីសមត្ថភាពធ្វើប្រតិបត្តិការនាំចូលនាំចេញជីកសិកម្មរបស់ក្រុមហ៊ុននៅក្នុងឆ្នាំចុងក្រោយមុនពេលស្នើសុំ។	០១ច្បាប់
៨- វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម(តាមទីតាំងនីមួយៗ)។	០១ច្បាប់
៩- វិក្កយបត្របង់កម្រៃសេវាកម្មសម្រាប់ការចេញលិខិតអនុញ្ញាតនាំចូលនាំចេញ។	០១ច្បាប់
១០- CD soft copy នៃបញ្ជីឈ្មោះជីកសិកម្មដែលស្នើសុំនាំចូលនាំចេញ គំរូសំបកវេចខ្ចប់ គំរូស្លាកសញ្ញាព័ត៌មាន ឬបរិយាយប័ណ្ណសម្រាប់ការណែនាំ ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត។	០១ច្បាប់

VI-ការស្នើសុំ

ខ្ញុំបាទឬនាងខ្ញុំជា...

សូមដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម ដោយបានបំពេញព័ត៌មាននិងភ្ជាប់ឯកសារគ្រប់គ្រាន់ជូនដូចខាងលើ និងសូមគោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

អ្នកស្នើសុំ

ហត្ថលេខា ឈ្មោះ និងត្រា

សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្មតែប៉ុណ្ណោះ (Department of Agricultural Legislation use only)
សាលាកបត្រប្រគល់-ទទួលសំណុំឯកសារ៖ លេខ កាលបរិច្ឆេទទួល៖ មន្ត្រីទទួលសំណុំឯកសារ៖ ហត្ថលេខា
សំណើសុំ ☐ **នាំចូល** ☐ **នាំចេញ**
បរិមាណស្នើសុំ៖ ចំនួន.................មុខ......បរិមាណ..
ប្រទេសប្រភពដើមនាំចេញ៖..
មធ្យោបាយដឹកជញ្ជូន៖ ....
មាត់ច្រក ៖ ....
វិក្កយបត្របង់កម្រៃសេវាកម្មចេញលិខិតអនុញ្ញាតលេខ៖..
កំណត់សម្គាល់៖... ....

កំណត់សម្គាល់៖

១- រាល់ឯកសារថតចម្លងដែលបញ្ជាក់អំពីព័ត៌មានទូទៅរបស់អ្នកស្នើសុំដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្រ ឬឯកសារផ្សេងទៀត ត្រូវភ្ជាប់ឬបង្ហាញច្បាប់ដើមដល់មន្ត្រីទទួលឯកសារនៃនាយកដ្ឋាននីតិកម្មកសិកម្ម ឬត្រូវមានសេចក្តីបញ្ជាក់លើឯកសារថតចម្លងទាំងនោះដោយសាលារាជធានី ខេត្តតាមនីតិវិធីជាធរមាន។

២- ក្នុងករណីតំណាងក្រុមហ៊ុនឬតំណាងនីតិបុគ្គលទទួលខុសត្រូវផ្ទាល់ក្នុងដំណើរការដាក់ពាក្យស្នើសុំនេះ ក្រុមហ៊ុនឬនីតិបុគ្គលនោះត្រូវចេញលិខិតប្រគល់សិទ្ធិឲ្យបុគ្គលនោះជាតំណាងស្របច្បាប់របស់ខ្លួន **ដោយត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិនេះជាមួយពាក្យស្នើសុំ។**

ខ-គំរូពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជកម្ម

I-ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ (General Information on the Applicant)	
១-ឈ្មោះអ្នកស្នើសុំ៖	
២-សញ្ជាតិ៖ អាយុ៖ ភេទ ៖	
៣-អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ៖ ផុតកំណត់ថ្ងៃទី៖	
៤-នីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជន៖ "គូសក្នុងប្រអប់"	
☐ ក្រសួង ស្ថាប័ន ឬអង្គភាពរដ្ឋ ☐ ឯកត្តជន ☐ ក្រុមហ៊ុនវិនិយោគដំណាំកសិឧស្សាហកម្ម	☐ សហគមន៍កសិកម្ម ☐ កសិដ្ឋានខ្នាតធំ ☐ នីតិបុគ្គលឯកជនផ្សេងទៀត៖
៥-អាសយដ្ឋាននៅកម្ពុជា៖	
ទូរសព្ទឬទូរសារ៖	
គេហទំព័រ៖	
៦-ចុះបញ្ជីពាណិជ្ជកម្ម៖ ចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត៖	
៧-ឃ្លាំងសន្និធិ	
លេខចុះបញ្ជី និងអាសយដ្ឋាន	
៨-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ "បើសិនជាមាន"	
៩-អត្តសញ្ញាណនៃប្រភពដើមលាយផ្សំឬផ្គត់ផ្គង់ចែកចាយ	
ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនប្រភពដើមផ្គត់ផ្គង់ចែកចាយ	
ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនប្រភពដើមលាយផ្សំ	

II-គោលបំណងនៃការស្នើសុំ (Purpose and state of application) "គូសក្នុងប្រអប់"	
☐ ធ្វើវិភាគនិងធ្វើការសាកល្បងលើទីវាលពិសោធន៍ ☐ ធ្វើការប្រើប្រាស់ដោយផ្ទាល់ ☐ ធ្វើអំណោយដល់សាធារណៈ	☐ ធ្វើការពិសោធឬស្រាវជ្រាវសម្រាប់វិស័យសាធារណៈ ☐ គោលបំណងមិនមែនពាណិជ្ជកម្មផ្សេងទៀត

III-មធ្យោបាយដឹកជញ្ជូន កំពង់ផែ ឬមាត់ច្រកដែលនាំចូលនាំចេញ (Mean of transport, port, or border entry to be imported-exported) "គូសក្នុងប្រអប់"	
មធ្យោបាយដឹកជញ្ជូន ៖ ☐ រថយន្ត ☐ នាវា ☐ យន្តហោះ ☐ មធ្យោបាយផ្សេងទៀត៖....................................	កំពង់ផែឬមាត់ច្រក ៖ ☐ កំពង់ផែ.. .... ☐ មាត់ច្រក.. ....

IV-យថាប្រភេទនិងបរិមាណជីកសិកម្មដែលស្នើសុំការនាំចូល (Specification & quantity of fertilizers to be imported) ☐ មានភ្ជាប់ CD ឬបញ្ជីដោយឡែក (បើសិនជាច្រើន)

ល.រ No	យថាប្រភេទជីកសិកម្ម Specification	ឈ្មោះពាណិជ្ជកម្ម Trade name	លេខបញ្ជិកា Registration N^{0}	បរិមាណស្នើនាំចូល Quantity to be imported	ក្រុមហ៊ុននិងប្រទេសប្រភពដើម Company/Country of origin
១					
២					
៣					
៤					
៥					
៦					
៧					
៨					
៩					
១០					
សរុបត្រឹមចំនួន៖....................មុខ បរិមាណ៖..............................					

V-បញ្ជីឯកសារត្រូវភ្ជាប់ជាមួយ (List of documents enclosed)	
១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ប័ណ្ណប៉ាតង់ ឬប័ណ្ណបង់ពន្ធលើផលរបរ(ITR)នៃឆ្នាំចុងក្រោយ ឬឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត។	០១ច្បាប់

២- ឯកសារឬកិច្ចសន្យាបញ្ជាក់ការផ្គត់ផ្គង់របស់ក្រុមហ៊ុនប្រភពដើម។	០១ច្បាប់
៣- លិខិតយថាភូតរបស់អ្នកស្នើសុំ (នីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជន)។	០១ច្បាប់
៤- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មតាមយថាប្រភេទនីមួយៗ ដែលត្រូវស្នើសុំនាំចូល។	០១ច្បាប់
៥- ព្រឹត្តិបត្របច្ចេកទេសប្រភពដើមនៃជីកសិកម្មជាភាសាខ្មែរ(តម្រូវតាមប្រភេទជីកសិកម្ម)។	០១ច្បាប់
៦- ព័ត៌មានស្តីពីប្រភេទដំណាំនិងផ្ទៃដីដែលត្រូវប្រើឬត្រូវពិសោធសាកល្បង បរិមាណសារធាតុចិញ្ចឹមឬផលិតផលជីកសិកម្មត្រូវប្រើ រយៈពេលធ្វើការសាកល្បង ឈ្មោះនិងទីតាំងនៃស្ថានីយពិសោធសាកល្បង និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធការប្រើប្រាស់ឬការពិសោធសាកល្បងជីកសិកម្ម។	០១ច្បាប់
៧-របាយការណ៍អំពីសមត្ថភាពធ្វើប្រតិបត្តិការនាំចូលនិងការប្រើប្រាស់ជីកសិកម្មរបស់អ្នកស្នើសុំនៅក្នុងឆ្នាំចុងក្រោយមុនពេលស្នើសុំ (សម្រាប់ក្រុមហ៊ុនវិនិយោគដំណាំកសិឧស្សាហកម្ម សហគមន៍កសិកម្ម កសិដ្ឋានខ្នាតធំ ឬនីតិបុគ្គលឯកជនផ្សេងទៀត)។	០១ច្បាប់
៨- វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម(តាមទីតាំងនីមួយៗ)។	០១ច្បាប់
៩- វិក្កយបត្របង់កម្រៃសេវាកម្មសម្រាប់ការចេញលិខិតអនុញ្ញាតនាំចូល។	០១ច្បាប់
១០- CD soft copy នៃបញ្ជីឈ្មោះជីកសិកម្មដែលស្នើសុំនាំចូល គំរូសំបកវេចខ្ចប់គំរូស្លាកសញ្ញាព័ត៌មាន ឬបរិយាយប័ណ្ណសម្រាប់ការណែនាំ និងព័ត៌មានផ្សេងទៀត។	០១ច្បាប់

VI-ការស្នើសុំ

ខ្ញុំបាទឬនាងខ្ញុំជា..

សូមដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជកម្ម ដោយបានបំពេញព័ត៌មាននិងភ្ជាប់ឯកសារគ្រប់គ្រាន់ជូនដូចខាងលើ និងសូមគោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយក្តីអនុគ្រោះ។

............................., ថ្ងៃទី ខែ ឆ្នាំ

អ្នកស្នើសុំ

ហត្ថលេខា ឈ្មោះ និងត្រា

សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្មតែប៉ុណ្ណោះ (Department of Agricultural Legislation use only)
សាលាកបត្រប្រគល់-ទទួលសំណុំឯកសារៈ លេខ កាលបរិច្ឆេទទទួលៈ មន្រ្តីទទួលសំណុំឯកសារៈ ហត្ថលេខា
សំណើសុំ ☐ នាំចូល ☐ នាំចេញ
បរិមាណស្នើសុំៈ ចំនួន...................... មុខ....... បរិមាណ..
ប្រទេសប្រភពដើមនាំចេញៈ..
មធ្យោបាយដឹកជញ្ជូនៈ ....
មាត់ច្រក ៈ ....
វិក្កយបត្របង់កម្រៃសេវាកម្មចេញលិខិតអនុញ្ញាតលេខៈ..
កំណត់សម្គាល់ៈ.. ....

កំណត់សម្គាល់ៈ

១- រាល់ឯកសារថតចម្លងដែលបញ្ជាក់អំពីព័ត៌មានទូទៅរបស់អ្នកស្នើសុំដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្រ ឬឯកសារផ្សេងទៀត ត្រូវភ្ជាប់ឬបង្ហាញច្បាប់ដើមដល់មន្ត្រីទទួលឯកសារនៃនាយកដ្ឋាននីតិកម្មកសិកម្ម ឬត្រូវមានសេចក្តីបញ្ជាក់លើឯកសារថតចម្លងទាំងនោះដោយសាលារាជធានី ខេត្តតាមនីតិវិធីជាធរមាន។

២-ក្នុងករណីតំណាងក្រុមហ៊ុនឬតំណាងនីតិបុគ្គលទទួលខុសត្រូវផ្ទាល់ក្នុងដំណើរការដាក់ពាក្យស្នើសុំនេះ ក្រុមហ៊ុនឬនីតិបុគ្គលនោះត្រូវចេញលិខិតប្រគល់សិទ្ធិឲ្យបុគ្គលនោះជាតំណាងស្របច្បាប់របស់ខ្លួនដោយត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិនេះជាមួយពាក្យស្នើសុំ។

31/01/2013

ខ-គំរូលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ....កសក /ននក

លិខិតអនុញ្ញាត
នាំចូលនាំចេញជីកសិកម្ម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរាជក្រមលេខ **នស/រកម/០១១២/០០៥** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

-បានឃើញប្រកាសលេខ..................**ប្រក/កសក** ចុះថ្ងៃទី............ខែ..........ឆ្នាំ.........ស្តីពីនីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម

-បានឃើញពាក្យស្នើសុំរបស់ក្រុមហ៊ុនលេខ..................................ចុះថ្ងៃទី........ខែ........ឆ្នាំ២០

សម្រេច

អនុញ្ញាតឲ្យ លោក/លោកស្រី..............................ជាប្រធានក្រុមហ៊ុន..............................

អាសយដ្ឋាន[illegible]... ។

ធ្វើការ☐**នាំចូល**☐**នាំចេញជីកសិកម្ម** បរិមាណសរុប:..☐មានបញ្ជីភ្ជាប់

១-..............................លេខបញ្ជិកា..............................ចំនួន..............................

២-..............................លេខបញ្ជិកា..............................ចំនួន..............................

៣-..............................លេខបញ្ជិកា..............................ចំនួន..............................

៤-..............................លេខបញ្ជិកា..............................ចំនួន..............................

៥-..............................លេខបញ្ជិកា..............................ចំនួន..............................

ច្រកពាណិជ្ជកម្ម[illegible] : ប្រទេសប្រភពដើមនាំចេញ..

ប្រទេសទិសដៅ[illegible]..............................មាត់ច្រក..

សុពលភាព លិខិតអនុញ្ញាតនេះត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់[illegible]អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម[illegible]មាន[illegible]រយៈពេល១២ខែ[illegible]គិតចាប់ពីថ្ងៃចេញ លិខិតអនុញ្ញាតនេះ និងត្រូវផុតសុពលភាព[illegible]ទី ខែ ឆ្នាំ លើកលែងតែ[illegible]ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ ថ្ងៃ ខែ ឆ្នាំ២០

រដ្ឋមន្ត្រី

ឧបសម្ពន្ធទី២ នៃប្រកាសលេខ...១២៩............ប្រក.កសក ចុះថ្ងៃទី.១១..ខែ.មេសាឆ្នាំ២០១៣

ស្តីពី **"នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម"**

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មី

ក-គំរូពាក្យស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មី ជីកសិកម្ម

I-ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ (General Information on the Applicant)	
១-ឈ្មោះអ្នកស្នើសុំ៖	
២-សញ្ជាតិ៖ អាយុ៖ ភេទ ៖	
៣-អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ៖ ផុតកំណត់ថ្ងៃទី៖	
៤-ក្រុមហ៊ុនឬនីតិបុគ្គលឯកជន៖ "គូសក្នុងប្រអប់"	
☐ លាយផ្សំ ☐ វេចខ្ចប់ជាថ្មី ☐ នាំចេញ ☐ ផ្គត់ផ្គង់ចែកចាយ ☐ សហគមន៍កសិកម្ម ☐ នីតិបុគ្គលឯកជនផ្សេងទៀត (បញ្ជាក់)៖	
៥-អាសយដ្ឋាននៅកម្ពុជា៖	
ទូរសព្ទឬទូរសារ៖	
គេហទំព័រ៖	
៦-ចុះបញ្ជីពាណិជ្ជកម្ម៖ ចុះបញ្ជីនីតិបុគ្គលផ្សេងទៀត៖	
៧-ឃ្លាំងសន្និធិ	
លេខចុះបញ្ជី និងអាសយដ្ឋាន	
៨-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ "បើសិនជាមាន"	
៩-អត្តសញ្ញាណនៃប្រភពលាយផ្សំឬផ្គត់ផ្គង់ចែកចាយ	
ឈ្មោះអ្នកលាយផ្សំនិងអាសយដ្ឋាននៃគ្រឹះស្ថានលាយផ្សំ	
លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី	

II-គោលបំណងនៃការស្នើសុំ (Purpose and state of application) "គូសក្នុងប្រអប់"	
☐ ការនាំចេញ ☐ ការវេចខ្ចប់ជាថ្មី ☐ ការផ្គត់ផ្គង់ចែកចាយ	☐ ការបន្តសុពលភាពលិខិតអនុញ្ញាត ☐ ការផ្ទេរសិទ្ធិលើលិខិតអនុញ្ញាត ☐ គោលបំណងពាណិជ្ជកម្មផ្សេងទៀត

III-យថាប្រភេទជីកសិកម្ម សមត្ថភាពផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី (Specification of fertilizers, production/repack capacity) ☐ មានភ្ជាប់ CD ឬបញ្ជីដោយឡែក (បើសិនជាច្រើន)

ល.រ No	យថាប្រភេទជីកសិកម្ម Specification	ឈ្មោះពាណិជ្ជកម្ម Trade name	លេខបញ្ជិកា Registration N⁰	សមត្ថភាពផលិតលាយផ្សំឬវេចខ្ចប់ជាថ្មីប្រចាំឆ្នាំ Annual production /repack capacity
១				
២				
៣				
៤				
៥				
៦				
៧				
៨				
៩				
១០				
សរុបត្រឹមចំនួន៖....................មុខ បរិមាណ៖.............................				

IV-បញ្ជីឯកសារត្រូវភ្ជាប់ជាមួយ (List of documents enclosed)	
១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ប័ណ្ណប៉ាតង់ ឬប័ណ្ណបង់ពន្ធលើផលរបរ(ITR)នៃឆ្នាំចុងក្រោយ ឬឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត។	០១ច្បាប់
២- ប្រកាសឬអាជ្ញាប័ណ្ណអនុញ្ញាតបង្កើតរោងចក្រ សិប្បកម្មផលិតលាយផ្សំជីកសិកម្ម ដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល។	០១ច្បាប់
៣- របាយការណ៍ត្រួតពិនិត្យដំណើរការលាយផ្សំឬវេចខ្ចប់ជាថ្មី នៅមុនពេលចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្ម។	០១ច្បាប់

៤- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មតាមយថាប្រភេទនីមួយៗ ដែលត្រូវធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី។	០១ច្បាប់
៥- សំបកវេចខ្ចប់ជីកសិកម្មតាមយថាប្រភេទនីមួយៗដែលមានស្លាកសញ្ញាព័ត៌មានឬបរិយាយប័ណ្ណសម្រាប់ការណែនាំជាភាសាខ្មែរ ដែលបានយល់ព្រមនៅពេលធ្វើការចុះបញ្ជី។	០១ច្បាប់
៦- លិខិតបញ្ជាក់របស់ក្រុមហ៊ុននូវអត្តសញ្ញាណបុគ្គលិកបច្ចេកទេសប្រចាំការគ្រឹះស្ថានលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្មរបស់ខ្លួន និងដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។	០១ច្បាប់
៧- របាយការណ៍អំពីសមត្ថភាពប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្ម របស់ក្រុមហ៊ុននៅក្នុងឆ្នាំចុងក្រោយមុនពេលស្នើសុំ។	០១ច្បាប់
៨- វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម(តាមទីតាំងនីមួយៗ)។	០១ច្បាប់
៦- វិក្កយបត្របង់កម្រៃសេវាកម្មសម្រាប់ការចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្ម។	០១ច្បាប់
១០- CD soft-copy នៃបញ្ជីយថាប្រភេទជីកសិកម្មដែលធ្វើប្រតិបត្តិការផលិតលាយផ្សំឬវេចខ្ចប់ជាថ្មី គំរូសំបកវេចខ្ចប់ គំរូស្លាកសញ្ញាព័ត៌មាន ឬបរិយាយប័ណ្ណសម្រាប់ការណែនាំ ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត។	០១ច្បាប់

V-ការស្នើសុំ

ខ្ញុំបាទឬនាងខ្ញុំជា...

សូមដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើប្រតិបត្តិការផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្ម ដែលមានព័ត៌មាននិងឯកសារភ្ជាប់ជូនដូចខាងលើ និងសូមគោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

អ្នកស្នើសុំ

ហត្ថលេខា ឈ្មោះ និងត្រា

សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្មតែប៉ុណ្ណោះ (Department of Agricultural Legislation use only)
សាលាកបត្រប្រគល់-ទទួលសំណុំឯកសារ៖ លេខ   កាលបរិច្ឆេទទួល៖ មន្ត្រីទទួលសំណុំឯកសារ៖   ហត្ថលេខា
សំណើសុំ   □ **ប្រតិបត្តិការផលិតលាយផ្សំ**   □ **វេចខ្ចប់ជាថ្មី**
ប្រភេទជីកសិកម្មស្នើសុំ៖...
សមត្ថភាពលាយផ្សំឬវេចខ្ចប់ជាថ្មីប្រចាំឆ្នាំ៖..
វិក្កយបត្របង់កម្រៃសេវាកម្មចេញលិខិតអនុញ្ញាតលេខ៖...
កំណត់សម្គាល់៖.. ....

កំណត់សម្គាល់៖

១- រាល់ឯកសារថតចម្លងដែលបញ្ជាក់អំពីព័ត៌មានទូទៅរបស់អ្នកស្នើសុំដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្រ ឬឯកសារផ្សេងទៀត ត្រូវភ្ជាប់ឬបង្ហាញច្បាប់ដើមដល់មន្ត្រីទទួលឯកសារនៃនាយកដ្ឋាននីតិកម្មកសិកម្ម ឬត្រូវមានសេចក្តីបញ្ជាក់លើឯកសារថតចម្លងទាំងនោះដោយសាលារាជធានី ខេត្តតាមនីតិវិធីជាធរមាន។

២-ក្នុងករណីតំណាងក្រុមហ៊ុនឬតំណាងនីតិបុគ្គលទទួលខុសត្រូវផ្ទាល់ក្នុងដំណើរការដាក់ពាក្យស្នើសុំនេះ ក្រុមហ៊ុនឬនីតិបុគ្គលនោះត្រូវចេញលិខិតប្រគល់សិទ្ធិឲ្យបុគ្គលនោះជាតំណាងស្របច្បាប់របស់ខ្លួន **ដោយត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិនេះជាមួយពាក្យស្នើសុំ។**

ខ-គំរូលិខិតអនុញ្ញាតប្រតិបត្តិការផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ....កសក/នទក.លជ

លិខិតអនុញ្ញាត

ប្រតិបត្តិការផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្ម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

-បានឃើញប្រកាសលេខ.............**ប្រក/កសក** ចុះថ្ងៃទី...........ខែ...........ឆ្នាំ........ស្ដីពីនីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម

-បានឃើញពាក្យស្នើសុំរបស់ក្រុមហ៊ុនលេខ.............................ចុះថ្ងៃទី.......ខែ.......ឆ្នាំ២០

សម្រេច

អនុញ្ញាតឱ្យៈ លោក/លោកស្រី.............................ជាប្រធានក្រុមហ៊ុន.............................

អាសយដ្ឋានក្រុមហ៊ុន.. ។

ធ្វើប្រតិបត្តិការ ☐ផលិតលាយផ្សំ ☐វេចខ្ចប់ជាថ្មីជីកសិកម្ម

សមត្ថភាពផលិតលាយផ្សំឬវេចខ្ចប់ជាថ្មីប្រចាំឆ្នាំ.............................តោន/ឆ្នាំ

ឈ្មោះ និងទីតាំងរោងស្ថានផលិតលាយផ្សំ.............................

....

សុពលភាពៈ លិខិតអនុញ្ញាតនេះត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំ ដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន ក្នុងសុពលភាពរយៈពេល៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ និងត្រូវផុតសុពលភាពនៅថ្ងៃទី ខែ ឆ្នាំ លើកលែងតែមានការដកហូតដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០

រដ្ឋមន្ត្រី

ឧបសម្ពន្ធទី៣ នៃប្រកាសលេខ...១១៩...........ប្រក.កសក ចុះថ្ងៃទី..២១.ខែ..មករា.ឆ្នាំ២០១៣
ស្តីពី "នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម"

គំរូសំណុំបែបបទសម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម

ក-គំរូពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម

I-**ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ** (General Information on the Applicant)
១-ឈ្មោះអ្នកស្នើសុំ៖
២-សញ្ជាតិ៖ អាយុ៖ ភេទ ៖
៣-អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ៖ ផុតកំណត់ថ្ងៃទី៖
៤-ក្រុមហ៊ុនឬនីតិបុគ្គលឯកជន៖ "គូសក្នុងប្រអប់"
☐ នាំចូលនាំចេញ ☐ ផ្គត់ផ្គង់ចែកចាយ ☐ លាយផ្សំ ☐ វេចខ្ចប់ជាថ្មី ☐ សហគមន៍កសិកម្ម ☐ ក្រុមហ៊ុនវិនិយោគដំណាំកសិឧស្សាហកម្ម ☐ នីតិបុគ្គលឯកជនផ្សេងទៀត(បញ្ជាក់)៖
៥-អាសយដ្ឋាននៅកម្ពុជា៖
ទូរសព្ទឬទូរសារ៖
គេហទំព័រ៖
៦-ចុះបញ្ជីពាណិជ្ជកម្ម៖ ចុះបញ្ជីនីតិបុគ្គលផ្សេងទៀត៖
៧-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ "បើសិនជាមាន"

II-**គោលបំណងនៃការស្នើសុំ** (Purpose and state of application) "គូសក្នុងប្រអប់"	
☐ ការនាំចូលនាំចេញ	☐ ការបន្តសុពលភាពវិញ្ញាបនបត្រ
☐ ការលាយផ្សំ	☐ ការផ្ទេរសិទ្ធិលើវិញ្ញាបនបត្រ
☐ ការវេចខ្ចប់ជាថ្មី	☐ ការប្រើប្រាស់ដោយផ្ទាល់
☐ ការផ្គត់ផ្គង់ចែកចាយ	☐ គោលបំណងផ្សេងទៀត

III-ទីតាំងឃ្លាំងសន្និធិជីកសិកម្ម (Location of Warehouse)

ល.រ No	ឈ្មោះឃ្លាំងសន្និធិ	អាសយដ្ឋាន	ផ្ទៃឃ្លាំងសន្និធិនិង សមត្ថភាពសន្និធិ
១			
២			
៣			
៤			
៥			

IV-បញ្ជីឯកសារត្រូវភ្ជាប់ជាមួយ (List of documents enclosed)

១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ប័ណ្ណប៉ាតង់ ឬប័ណ្ណបង់ពន្ធលើផលរបរ(ITR)នៃឆ្នាំចុងក្រោយ ឬឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត។	០១ច្បាប់
២- លិខិតអនុញ្ញាតដែលមានសុពលភាព ☐-នាំចូលនាំចេញ ☐-ប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី ☐-ផ្គត់ផ្គង់ចែកចាយ ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។	០១ច្បាប់
៣- របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃលើទីតាំងឃ្លាំងសន្និធិ ដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម នៅមុនពេលធ្វើការចុះបញ្ជី។	០១ច្បាប់
៤- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មតាមយថាប្រភេទនីមួយៗ ដែលត្រូវធ្វើសន្និធិនៅក្នុងឃ្លាំង។	០១ច្បាប់
៥- របាយការណ៍អំពីសមត្ថភាពធ្វើប្រតិបត្តិការសន្និធិជីកសិកម្ម របស់ក្រុមហ៊ុនក្នុងឆ្នាំចុងក្រោយមុនពេលស្នើសុំ។	០១ច្បាប់
៦- វិក្កយបត្របង់កម្រៃសេវាកម្មសម្រាប់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម។	០១ច្បាប់

V- ការស្នើសុំ

ខ្ញុំបាទឬនាងខ្ញុំជា...

សូមដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម ដែលមានព័ត៌មាននិងឯកសារភ្ជាប់ជូនដូចខាងលើ និងសូមគោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

អ្នកស្នើសុំ

ហត្ថលេខា ឈ្មោះ និងត្រា

សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្មតែប៉ុណ្ណោះ (Department of Agricultural Legislation use only)	
សាលាកបត្រប្រគល់-ទទួលសំណុំឯកសារៈ លេខ មន្ត្រីទទួលសំណុំឯកសារៈ	កាលបរិច្ឆេទទួលៈ ហត្ថលេខា
សំណើសុំ □ **ប្រតិបត្តិការផលិតលាយជី**	□ **វេចខ្ចប់ជាថ្មី**
ចំនួនឃ្លាំងសន្និធិស្នើសុំៈ..	
វិក្កយបត្របង់កម្រៃសេវាកម្មសម្រាប់ការចុះបញ្ជីឃ្លាំងសន្និធិៈ..	
កំណត់សម្គាល់ៈ..	

កំណត់សម្គាល់ៈ

១- រាល់ឯកសារថតចម្លងដែលបញ្ជាក់អំពីព័ត៌មានទូទៅរបស់អ្នកស្នើសុំដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្រ ឬឯកសារផ្សេងទៀត ត្រូវភ្ជាប់ឬបង្ហាញច្បាប់ដើមដល់មន្ត្រីទទួលឯកសារនៃនាយកដ្ឋាននីតិកម្មកសិកម្ម ឬត្រូវមានសេចក្តីបញ្ជាក់លើឯកសារថតចម្លងទាំងនោះដោយសាលារាជធានី ខេត្តតាមនីតិវិធីជាធរមាន។

២-ក្នុងករណីតំណាងក្រុមហ៊ុនឬតំណាងនីតិបុគ្គលទទួលខុសត្រូវផ្ទាល់ក្នុងដំណើរការដាក់ពាក្យស្នើសុំនេះ ក្រុមហ៊ុនឬនីតិបុគ្គលនោះ ត្រូវចេញលិខិតប្រគល់សិទ្ធិឲ្យបុគ្គលនោះជាតំណាងស្របច្បាប់របស់ខ្លួន **ដោយត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិនេះជាមួយពាក្យស្នើសុំ។**

ខ-គំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងជីកសិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ....កសក /ននក

វិញ្ញាបនបត្រ
បញ្ជាក់ការចុះបញ្ជីឃ្លាំងជីកសិកម្ម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បានឃើញរាជក្រមលេខ នស/រកម/០១១២/០០៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
បានឃើញប្រកាសលេខ............/ប្រក.កសក ចុះថ្ងៃទី.........ខែ.............ឆ្នាំ.........ស្តីពីនីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
បានឃើញពាក្យស្នើសុំរបស់ក្រុមហ៊ុនលេខ..............................ចុះថ្ងៃទី........ខែ........ឆ្នាំ២០

សូមបញ្ជាក់ថា

ឈ្មោះនិងទីតាំងឃ្លាំងសន្និធិ៖ ....
....
មានសមត្ថភាពស្តុកសន្និធិប្រចាំឆ្នាំ..............................តោន **ផ្ទៃសន្និធិ**.............................ម៉ែត្រការ៉េ
ត្រូវបានចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មរបស់ លោក/លោកស្រី..
ជាប្រធានក្រុមហ៊ុន...................................មានអាសយដ្ឋានអចិន្ត្រៃយ៍.......................................
....
លេខបញ្ជិកាឃ្លាំង៖...
សុពលភាព វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន ក្នុងសុពលភាពរយៈពេល៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាវិញ្ញាបនបត្រនេះ និងត្រូវផុតសុពលភាពនៅថ្ងៃទី ខែ ឆ្នាំ២០ លើកលែងតែមានការដកហូតដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០
រដ្ឋមន្ត្រី

ឧបសម្ពន្ធទី៤ នៃប្រកាសលេខ...១១៨..............ប្រក.កសក ចុះថ្ងៃទី១១..ខែ.[illegible].ឆ្នាំ២០១៣

ស្តីពី "**នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម**"

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម

ក-គំរូពាក្យស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម

I-**ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ** (General Information on the Applicant)	
១-ឈ្មោះអ្នកស្នើសុំ៖	
២-សញ្ជាតិ៖ អាយុ៖ ភេទ ៖	
៣-អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ៖ ផុតកំណត់ថ្ងៃទី៖	
៤-ក្រុមហ៊ុនឬនីតិបុគ្គលឯកជន៖ "គូសក្នុងប្រអប់"	
☐ នាំចូលនាំចេញ ☐ វេចខ្ចប់ជាថ្មី ☐ លាយផ្សំ ☐ ផ្គត់ផ្គង់ចែកចាយ ☐ សហគមន៍កសិកម្ម ☐ នីតិបុគ្គលឯកជនផ្សេងទៀត(បញ្ជាក់)៖	
៥-អាសយដ្ឋាននៅកម្ពុជា៖	
ទូរសព្ទឬទូរសារ៖	
គេហទំព័រ៖	
៦-ចុះបញ្ជីពាណិជ្ជកម្ម៖ **ចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត៖**	
៧-ឃ្លាំងសន្និធិ	
លេខចុះបញ្ជី និងអាសយដ្ឋាន	
៨-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ "បើសិនជាមាន"	
៩-អត្តសញ្ញាណនៃប្រភពលាយផ្សំឬផ្គត់ផ្គង់ចែកចាយ	
ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនប្រភពដើមផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម(ករណីនាំចូល)	
ឈ្មោះអ្នកលាយផ្សំនិងអាសយដ្ឋាននៃគ្រឹះស្ថានលាយផ្សំថ្នាំកសិកម្ម(ករណីផលិតក្នុងស្រុក)	

II-គោលបំណងនៃការស្នើសុំ (Purpose and state of application) "គូសក្នុងប្រអប់"	
☐ ការផ្គត់ផ្គង់ចែកចាយ ☐ ការផ្ទេរសិទ្ធិលើលិខិតអនុញ្ញាត	☐ ការបន្តសុពលភាពលិខិតអនុញ្ញាត ☐ គោលបំណងផ្សេងទៀត

III-យថាប្រភេទនិងបរិមាណជីកសិកម្មដែលស្នើសុំការផ្គត់ផ្គង់ចែកចាយ (Specification & quantity of fertilizers to be distributed) ☐ មានភ្ជាប់ CD ឬបញ្ជីដោយឡែក (បើសិនជាច្រើន)

ល.រ No	យថាប្រភេទ ជីកសិកម្ម Specification	ឈ្មោះពាណិជ្ជកម្ម Trade name	លេខបញ្ជិកា Registration N^0	បរិមាណផ្គត់ផ្គង់ ចែកចាយប្រចាំឆ្នាំ Annual quantity to be distributed	ក្រុមហ៊ុននិងប្រទេស ប្រភពដើម Company & Country of origin
១					
២					
៣					
៤					
៥					
៦					
៧					
៨					
៩					
១០					
សរុបត្រឹមចំនួន៖....................មុខ បរិមាណ៖.............................					

IV-បញ្ជីឯកសារត្រូវភ្ជាប់ជាមួយ (List of documents enclosed)	
១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ប័ណ្ណប៉ាតង់ ឬប័ណ្ណបង់ពន្ធលើផលរបរ(ITR)នៃឆ្នាំចុងក្រោយ ឬឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត។	០១ច្បាប់
២- ☐លិខិតអនុញ្ញាតនាំចូល ☐លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្មរបស់ក្រុមហ៊ុនដើមដែលផ្គត់ផ្គង់ចែកចាយដោយផ្ទាល់ ឬសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់ចែកចាយបន្ត។	០១ច្បាប់
៣- កិច្ចសន្យាបញ្ជាក់ការផ្គត់ផ្គង់របស់ក្រុមហ៊ុនដើម សម្រាប់ការស្នើសុំផ្គត់ផ្គង់ចែកចាយបន្ត។	០១ច្បាប់
៤- វិក្កយបត្របណ្តោះអាសន្នបញ្ជាក់ថ្លៃជីកសិកម្មតាមយថាប្រភេទ ដែលស្នើសុំផ្គត់ផ្គង់ចែកចាយ។	០១ច្បាប់

៥- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មតាមយថាប្រភេទនីមួយៗ ដែលត្រូវស្នើសុំផ្គត់ផ្គង់ចែកចាយ។	០១ច្បាប់
៦- សំបកវេចខ្ចប់ជីកសិកម្មតាមប្រភេទនីមួយៗដែលមានស្លាកសញ្ញាព័ត៌មានឬបរិយាយប័ណ្ណសម្រាប់ការណែនាំជាភាសាខ្មែរដែលបានយល់ព្រមនៅពេលធ្វើការចុះបញ្ជី។	០១ច្បាប់
៧- របាយការណ៍អំពីសមត្ថភាពធ្វើប្រតិបត្តិការផ្គត់ផ្គង់ចែកចាយជីកសិកម្មរបស់អ្នកស្នើសុំនៅក្នុងឆ្នាំចុងក្រោយមុនពេលស្នើសុំ។	០១ច្បាប់
៨- បញ្ជីឈ្មោះ អត្តសញ្ញាណ អាស័យដ្ឋាន របស់សាខា គ្រឹះស្ថានលក់ដុំលក់រាយ ឬកសិដ្ឋាន តាមរាជធានី ខេត្តនីមួយៗដែលចុះកិច្ចសន្យាទទួលយកការផ្គត់ផ្គង់ចែកចាយជីកសិកម្មរបស់ក្រុមហ៊ុនសាមី។	០១ច្បាប់
៩- វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម(តាមទីតាំងនីមួយៗ)។	០១ច្បាប់
១០- វិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដែលរៀបចំដោយមន្ទីរកសិកម្មរាជធានី ខេត្តសាមី(សម្រាប់អ្នកផ្គត់ផ្គង់ចែកចាយបន្ត)។	០១ច្បាប់
១១- វិក្កយបត្របង់កម្រៃសេវាកម្មសម្រាប់ការចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ។	០១ច្បាប់
១២- CD soft copy នៃបញ្ជីឈ្មោះជីកសិកម្មដែលស្នើសុំផ្គត់ផ្គង់ចែកចាយគំរូសំបកវេចខ្ចប់ គំរូស្លាកសញ្ញាព័ត៌មាន ឬបរិយាយប័ណ្ណសម្រាប់ការណែនាំ ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត។	០១ច្បាប់

V- ការស្នើសុំ

ខ្ញុំបាទ/នាងខ្ញុំជា...

សូមដាក់ពាក្យស្នើសុំធ្វើលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម ដែលមានព័ត៌មាននិងឯកសារភ្ជាប់ជូនដូចខាងលើ និងសូមគោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

អ្នកស្នើសុំ

ហត្ថលេខា ឈ្មោះ និងត្រា

សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្មតែប៉ុណ្ណោះ (Department of Agricultural Legislation use only)
សាលាកបត្រប្រគល់-ទទួលសំណុំឯកសារ៖ លេខ កាលបរិច្ឆេទទួល៖ មន្ត្រីទទួលសំណុំឯកសារ៖ ហត្ថលេខា
ប្រភេទជីកសិកម្មស្នើសុំ៖..
បរិមាណស្នើសុំប្រចាំឆ្នាំ៖..
វិក្កយបត្របង់កម្រៃសេវាកម្មចេញលិខិតអនុញ្ញាតលេខ៖..
កំណត់សម្គាល់៖.. ....

កំណត់សម្គាល់៖

១- រាល់ឯកសារថតចម្លងដែលបញ្ជាក់អំពីព័ត៌មានទូទៅរបស់អ្នកស្នើសុំដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្រ ឬឯកសារផ្សេងទៀត ត្រូវភ្ជាប់ឬបង្ហាញច្បាប់ដើមដល់មន្ត្រីទទួលឯកសារនៃនាយកដ្ឋាននីតិកម្មកសិកម្ម ឬត្រូវមានសេចក្តីបញ្ជាក់លើឯកសារថតចម្លងទាំងនោះដោយសាលារាជធានី ខេត្តតាមនីតិវិធីជាធរមាន។

២-ក្នុងករណីតំណាងក្រុមហ៊ុនឬតំណាងនីតិបុគ្គលទទួលខុសត្រូវផ្ទាល់ក្នុងដំណើរការដាក់ពាក្យស្នើសុំនេះ ក្រុមហ៊ុនឬនីតិបុគ្គលនោះត្រូវចេញលិខិតប្រគល់សិទ្ធិឲ្យបុគ្គលនោះជាតំណាងស្របច្បាប់របស់ខ្លួន **ដោយត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិនេះជាមួយពាក្យស្នើសុំ។**

ឧបសម្ពន្ធទី៥ នៃប្រកាសលេខ....១១៩............ប្រក.កសក ចុះថ្ងៃទី.១១..ខែ.មករា..ឆ្នាំ២០១៣

ស្តីពី "**នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម**"

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម

ក-គំរូពាក្យស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម

I-**ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ** (General Information on the Applicant)		
១-ឈ្មោះអ្នកស្នើសុំ៖		
២-សញ្ជាតិ៖	អាយុ៖	ភេទ ៖
៣-អត្តសញ្ញាណបណ្ណលេខ ៖	ផុតកំណត់ថ្ងៃទី៖	
៤-គ្រឹះស្ថានលក់ដុំលក់រាយ ឬសាខារបស់ក្រុមហ៊ុនដើមនាំចូលនាំចេញ លាយផ្សំ វេចខ្ចប់ជាថ្មី ផ្គត់ផ្គង់ចែកចាយ៖		
ឈ្មោះសាខារបស់ក្រុមហ៊ុនដើម៖		
ឈ្មោះគ្រឹះស្ថាន៖		
អាសយដ្ឋាន៖		
ទូរសព្ទឬទូរសារ៖		
៦-ឃ្លាំងសន្និធិ		

លេខចុះបញ្ជី និងអាសយដ្ឋាន	

II-**គោលបំណងនៃការស្នើសុំ** (Purpose and state of application) "គូសក្នុងប្រអប់"	
☐ ការលក់ដុំលក់រាយ	☐ ការបន្តសុពលភាពលិខិតអនុញ្ញាត
☐ ការផ្ទេរសិទ្ធិលើលិខិតអនុញ្ញាត	☐ គោលបំណងផ្សេងទៀត

ខ-គំរូលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ....កសក /ននក.ផជ

លិខិតអនុញ្ញាត
ផ្គត់ផ្គង់ចែកចាយជីកសិកម្ម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញព្រះរាជក្រមលេខ [illegible] ២០០[illegible] [illegible] ប្បញ្ញត្តិស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសលេខ.......[illegible] ការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
- បានឃើញពាក្យស្នើសុំរបស់ក្រុមហ៊ុន [illegible]..................ចុះថ្ងៃទី [illegible]........ឆ្នាំ២០

សម្រេច

អនុញ្ញាតឲ្យ៖ លោក/លោកស្រី..............................ជាប្រធានក្រុមហ៊ុន..............................សាខារបស់ក្រុមហ៊ុន..............................
អាសយដ្ឋានអចិន្ត្រៃយ៍ ....។

ធ្វើប្រតិបត្តិការផ្គត់ផ្គង់ចែកចាយជីកសិកម្ម៖ ប្រ[illegible]បរិមាណជីកសិកម្មត្រូវផ្គត់ផ្គង់ចែកចាយប្រចាំឆ្នាំ ត្រូវយោង[illegible]ពាក្យស្នើសុំធ្វើការផ្គត់ផ្គង់ចែកចាយ។

សុពលភាព៖ លិខិតអនុញ្ញាតនេះត្រូវបានប្រគល់ជូនសាមីជនស្នើសុំដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន ក្នុងសុពលភាពរយៈពេល៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត [illegible] ឆ្នាំ២០ លើកលែងតែមានការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០

រដ្ឋមន្ត្រី

III-យថាប្រភេទនិងបរិមាណជីកសិកម្មដែលស្នើសុំការលក់ដុំលក់រាយ (Specification & quantity of fertilizers to be sold) □ មានភ្ជាប់ CD ឬបញ្ជីដោយឡែក (បើសិនជាច្រើន)

ល.រ No	យថាប្រភេទ ជីកសិកម្ម Specification	ឈ្មោះពាណិជ្ជកម្ម Trade name	លេខបញ្ជិកា Registration N^0	បរិមាណស្នើសុំលក់ដុំលក់រាយប្រចាំឆ្នាំ Annual quantity to be sold	ក្រុមហ៊ុនដើមផ្គត់ផ្គង់ចែកចាយ Company of distribution origin
១					
២					
៣					
៤					
៥					
៦					
៧					
៨					
៩					
១០					
សរុបត្រឹមចំនួន៖....................មុខ បរិមាណ៖..............................					

IV-**បញ្ជីឯកសារត្រូវភ្ជាប់ជាមួយ** (List of documents enclosed)	
១- ប័ណ្ណប៉ាតង់ ឬប័ណ្ណបង់ពន្ធលើផលរបរ(ITR)នៃឆ្នាំចុងក្រោយ។	០១ច្បាប់
២-វិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដែលរៀបចំដោយមន្ទីរកសិកម្មរាជធានី ខេត្ត សាមី។	០១ច្បាប់
៣- បញ្ជីឈ្មោះ អត្តសញ្ញាណ អាសយដ្ឋានរបស់ក្រុមហ៊ុនដើមដែលធ្វើការផ្គត់ផ្គង់ចែកចាយជីកសិកម្ម ដល់គ្រឹះស្ថានលក់ដុំលក់រាយ។	០១ច្បាប់
៤- វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម(ក្នុងករណីលក់ដុំ)។	០១ច្បាប់
៥- វិក្កយបត្របង់កម្រៃសេវាកម្មសម្រាប់ការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយ។	០១ច្បាប់

V- ការស្នើសុំ

ខ្ញុំបាទឬនាងខ្ញុំជាម្ចាស់គ្រឹះស្ថានលក់ដុំលក់រាយជីកសិកម្ម សូមដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម ដែលមានព័ត៌មាននិងឯកសារភ្ជាប់ជូនដូចខាងលើ និងសូមគោរពស្នើសុំការពិនិត្យសម្រេចរបស់លោកប្រធានមន្ទីរកសិកម្ម ឬលោកប្រធានការិយាល័យច្រកចេញចូលតែមួយ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.............................,ថ្ងៃទី ខែ ឆ្នាំ

អ្នកស្នើសុំ

ហត្ថលេខា ឬស្នាមមេដៃ និងឈ្មោះ

សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្មតែប៉ុណ្ណោះ (Department of Agricultural Legislation use only)	
សាលាកបត្រប្រគល់-ទទួលសំណុំឯកសារ៖ លេខ	កាលបរិច្ឆេទទទួល៖
មន្ត្រីទទួលសំណុំឯកសារ៖	ហត្ថលេខា
ប្រភេទជីកសិកម្មស្នើសុំ៖..	
បរិមាណស្នើសុំ៖ ចំនួន...............................មុខ បរិមាណប្រចាំឆ្នាំ..	
វិក្កយបត្របង់កម្រៃសេវាកម្មចេញលិខិតអនុញ្ញាតលេខ៖...	
កំណត់សម្គាល់៖..	

កំណត់សម្គាល់៖

១- រាល់ឯកសារថតចម្លងដែលបញ្ជាក់អំពីព័ត៌មានទូទៅរបស់អ្នកស្នើសុំដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្រ ឬឯកសារផ្សេងទៀត ត្រូវភ្ជាប់ឬបង្ហាញច្បាប់ដើមដល់មន្ត្រីទទួលឯកសារនៃនាយកដ្ឋាននីតិកម្មកសិកម្ម ឬត្រូវមានសេចក្តីបញ្ជាក់លើឯកសារថតចម្លងទាំងនោះដោយសាលារាជធានី ខេត្តតាមនីតិវិធីជាធរមាន។

២- ក្នុងករណីម្ចាស់គ្រឹះស្ថានលក់ដុំលក់រាយជីកសិកម្ម ចាត់តាំងតំណាងរបស់ខ្លួន ដើម្បីទទួលខុសត្រូវក្នុងដំណើរការដាក់ពាក្យស្នើសុំនេះ ម្ចាស់គ្រឹះស្ថានត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិឲ្យបុគ្គលនោះជាមួយពាក្យស្នើសុំ។

ខ-គំរូលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម

(១)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្ម..

លេខ ....មក/កនក

រូបថត
4x6សម

លិខិតអនុញ្ញាត
លក់ដុំលក់រាយជីកសិកម្ម

យោង៖ -ព្រះរាជក្រមលេខ **នស/រកម/០១១**[illegible] ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ប្រកាសឱ្យប្រើ[illegible]ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
-ប្រកាសលេខ...............**ប្រក/កសក** [illegible] ខែ.............ឆ្នាំ.......[illegible]កសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
-ពាក្យស្នើសុំរបស់...ចុះថ្ងៃទី...............ខែ...............ឆ្នាំ២០....

អនុញ្ញាតឱ្យ៖ ឈ្មោះ.....................................ភេទ...........ឆ្នាំកំណើត...............សញ្ជាតិ...............សាខារបស់ក្រុមហ៊ុន ....
អាសយដ្ឋានអចិន្ត្រៃយ៍...។

ធ្វើប្រតិបត្តិការលក់ដុំលក់រាយថ្នាំកសិកម្ម៖ ប្រភេទនិងបរិមាណជីកសិកម្មធ្វើការលក់ដុំលក់រាយប្រចាំឆ្នាំ ត្រូវយោងតាមពាក្យស្នើសុំធ្វើការលក់ដុំលក់រាយ។

ឈ្មោះនិងទីតាំងគ្រឹះស្ថានលក់ដុំលក់រាយ៖ ....។

សុពលភាព លិខិតអនុញ្ញាតនេះត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន ក្នុងសុពលភាពរយៈពេល**៣**ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ និងត្រូវផុតសុពលភាពនៅថ្ងៃទី ខែ ឆ្នាំ លើកលែងតែមានការដកហូតដោយមន្ទីរកសិកម្មនៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានី-ខេត្ត..................... ថ្ងៃទី ខែ ឆ្នាំ២០

ប្រធានមន្ទីរកសិកម្ម **ប្រធានការិយាល័យនីតិកម្មកសិកម្ម**

ខ-គំរូលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម

(២)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលា...
ការិយាល័យច្រកចេញចូលតែមួយ

លេខ ....

រូបថត
4x6សម

លិខិតអនុញ្ញាត
លក់ដុំលក់រាយជីកសិកម្ម

យោង៖
- ព្រះរាជក្រមលេខ **នស/រកម/០១១២/០០៥** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ [illegible] គ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- ប្រកាសលេខ..............**ប្រក/កសក** ចុះ[illegible] ធ្វើពាណិជ្ជកម្ម
- ប្រកាសលេខ ៤២១ប្រក/កសក ចុះថ្ងៃទី០៤ [illegible] ការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុកគោល[illegible]
- ពាក្យស្នើសុំរបស់.................................... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ២០......

អនុញ្ញាតឱ្យ៖ ឈ្មោះ.................................... ភេទ.......... ឆ្នាំកំណើត.......... សញ្ជាតិ.......... សាខារបស់ក្រុមហ៊ុន ....
អាសយដ្ឋានអចិន្ត្រៃយ៍...។
ធ្វើប្រតិបត្តិការលក់ដុំលក់រាយថ្នាំកសិកម្ម៖ ប្រភេទ[illegible]បរិមាណជីកសិកម្មដែលធ្វើការលក់ដុំលក់រាយប្រចាំឆ្នាំ ត្រូវ[illegible]ពាក្យស្នើសុំធ្វើការលក់ដុំលក់រាយ។
ឈ្មោះនិងទីតាំងគ្រឹះស្ថានលក់ដុំលក់រាយ៖ ....។

សុពលភាព៖ លិខិតអនុញ្ញាតនេះត្រូវបានប្រគល់ជូនសាមី[illegible]ប្រើប្រាស់ដោយអនុលោមតាមច្បាប់[illegible]គ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន ក្នុងសុពលភាពរយៈពេល៣(បី)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ [illegible] លើកលែងតែមានការដកហូតដោយមន្ទីរកសិកម្មនៅមុនកាលបរិច្ឆេទផុតសុពលភាព។

.... ថ្ងៃទី ខែ ឆ្នាំ២០

អភិបាលនៃគណៈអភិបាល.......................................